# មិត្តនគរបាល
POLICEFRIENDSHIPMAGAZINE

ទស្សនាវដ្ដី

លេខ ១០៦/ កក្កដា-សីហា / ២០២២

អរគុណសន្តិភាព









យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង

# គណៈកម្មការនិពន្ធ

## នាយកគ្រប់គ្រង

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ប៊ុនណារិន**

## និពន្ធនាយក

ឧត្តមសេនីយ៍ឯក សៀង សុវត្ថិ

## និពន្ធនាយករង

ឧត្តមសេនីយ៍ទោ ប៉ុក សុជាតិ

វរសេនីយ៍ឯក ប៉ុក រដ្ឋា



## យកព័ត៌មាន និពន្ធ

-វរសេនីយ៍ទោ ចាប ភ័ស្ត (ប្រធានក្រុម)
-វរសេនីយ៍ត្រី ប៉ុក គន្ធារ៉ូ
-អនុសេនីយ៍ឯក គន សេរី

## ថតរូប

-វរសេនីយ៍ទោ ជិន ម៉ូលីដា (ប្រធានក្រុម)
-អនុសេនីយ៍ឯក ស្រ៊ី ឈុនឡេង
-អនុសេនីយ៍ឯក លន់ ឈាងសេង
-អនុសេនីយ៍ឯក ព្រំ ចាន់តារា

## ចែកផ្សាយ

-វរសេនីយ៍ទោ ង៉ាន សុផាប (ប្រធានក្រុម)
-វរសេនីយ៍ត្រី សុន សៀង

## រចនាទំព័រ

-អនុសេនីយ៍ឯក ម៉ុង រិទ្ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក អ៊ុន ពិសិទ្ធ

## ពិនិត្យអក្ខរាវិរុទ្ធ

-វរសេនីយ៍ទោ ញឹម ហឿន (ប្រធានក្រុម)
-អនុសេនីយ៍ឯក វ៉ាន់ វិបុល

## កីឡា និងសិល្បៈ

-វរសេនីយ៍ត្រី ជឹម ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក មុត សីហា





# មាតិកា

## ព័ត៌មានថ្នាក់ដឹកនាំ


១-គ.ជ.ប. បូកសរុបការងារបោះឆ្នោតជ្រើសរើស..........០១
២-សម្តេចក្រឡាហោមទទួលជួបពិភាក្សាការងារ.........០៣
៣-សម្តេចក្រឡាហោម អនុញ្ញាតិឱ្យក្រុមនិស្សិត.........០៥
៤-សម្តេចក្រឡាហោម អញ្ជើញជាអធិបតីក្នុងពិធី.......០៧
៥-វគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាលកម្រិត១................០៩
៦-សម្តេចក្រឡាហោមអនុញ្ញាតឱ្យអនុរដ្ឋមន្ត្រី............១១
៧-សម្តេចក្រឡាហោម អញ្ជើញពិនិត្យវឌ្ឍនភាព.........១៣
៨-ឆមាសទី១ ឆ្នាំ២០២២ ក្នុងចំណោមអ្នកជិះម៉ូតូ .......១៥
៩-បណ្ឌិត្យសភានគរបាលកម្ពុជា...............................១៧
១០-ក្រសួងមហាផ្ទៃ និងអង្គការ IJM ចុះហត្ថលេខា......១៩
១១-អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលរៀបចំ............២១
១២-ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត .............២៣
១៣-សម្តេចក្រឡាហោម «មកជួយឱ្យល្អ កែបើធ្វើមិន..២៥
១៤-សម្តេចក្រឡាហោម អញ្ជើញដឹកនាំ....................២៩
១៥-សម្តេចក្រឡាហោមអញ្ជើញដឹកនាំកិច្ចប្រជុំ .........៣១
១៦-ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត................៣៣
១៧-អគ្គលេខាធិការ គ.ជ.ប.ជ បើកកិច្ចប្រជុំពិភាក្សា......៣៥
១៨-ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ូ សាគុណ ...........៣៧
១៩-អគ្គស្នងការរងនគរបាលជាតិជំរុញឱ្យមន្ត្រី.............៥១
២០-អគ្គស្នងការដ្ឋាននគរបាលជាតិ ដាក់ចេញ.............៥៣
២១-នគរបាលបច្ចេកទេសព្រំដែនចុះត្រួតពិនិត្យ...........៥៥
២២-កម្លាំងនគរបាលអន្តរាគមន៍ពិសេស....................៦១


## អត្ថបទសុខភាព


១-មើមខ្ញី អាចបន្សាបជាតិពុលក្នុងរាងកាយ កាត់បន្ថយជាតិខ្លាញ់ .......៤២


## អត្ថបទស្រាវជ្រាវ


១-អ្វីជាជម្ងឺអុតស្វា.........................................................................៥៧


## សកម្មភាពសមាគមមិត្តនគរបាលជាតិកម្ពុជា


១- ប្រគល់ថវិកា ស ម ន..........................................................................៦៣



# គ ជ ប បូកសរុបការងារបោះឆ្នោតជ្រើសរើស





នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គ.ជ.ប**) ដែលរៀបចំធ្វើនៅខេត្តព្រះសីហនុ ។

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ (**គ.ជ.ប**) បានបញ្ជាក់ឱ្យដឹងថា៖ បើទោះបីជាដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ បានឆ្លងកាត់ការលំបាកមួយចំនួន ដូចជាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ គ្រោះធម្មជាតិភ្លៀង ជំនន់ ព្រមទាំងខ្យល់កន្ត្រាក់នៅតំបន់ខ្លះ និងប្រឈមបញ្ហាបច្ចេកទេសមួយចំនួន ប៉ុន្តែការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយរលូនតាមច្បាប់ បទបញ្ញា នីតិវិធីនៃការបោះឆ្នោត និងប្រតិទិនកំណត់ ក្នុងបរិយាកាស



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# គ្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ ២០២២

ប្រកបដោយសន្តិសុខ សុវត្ថិភាព មាន សណ្តាប់ធ្នាប់ល្អ គ្មានអំពើហិង្សា និងការ គំរាមកំហែង ។

ឯកឧត្តម អគ្គលេខាធិការ **គ.ជ.ប** បានបញ្ជាក់ទៀតថា ក្រោយការបោះឆ្នោត នេះ គណបក្សឈរឈ្មោះបោះឆ្នោត និង អង្គការសង្កេតការណ៍ជាតិភាគច្រើន បាន ចេញសេចក្តីថ្លែងការណ៍គាំទ្រនិងកោត

៥០



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ ( គ.ជ.ប )





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម ឧបការី រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការ អាស៊ីបូព៌ា និង ប៉ាស៊ីហ្វិក



រសៀលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ដានីញ៉ែល ជេ គ្រីថេនប្រ៊ីង** (Daniel J. Kriten - brink) ឧបការីរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និង ប៉ាស៊ីហ្វិក ។

នៅក្នុងជំនួបនោះ **សម្តេចក្រឡាហោម** បានថ្លែងនូវការស្វាគមន៍ និងចាត់ទុកដំណើរទស្សនកិច្ចរបស់ ឯកឧត្តម ឧបការីរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក និងសហការីមកកាន់កម្ពុជានាពេលនេះ ថា ជាការរួមចំណែកមួយ ដល់ការលើកកម្ពស់នូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកម្ពុជា និងសហរដ្ឋអាមេរិក ។ ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍សម្តែងការអបអរសាទរចំពោះលទ្ធផល និងសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនារយៈពេលកន្លងមកនេះ ជាពិសេស នៅក្នុងឱកាសដែលកម្ពុជាទទួលតួនាទីជាប្រធានអាស៊ានប្តូរវេនក្នុងឆ្នាំ២០២២នេះ ។

**សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍ អបអរសាទរចំពោះកិច្ចប្រជុំកំពូលអាស៊ានសហរដ្ឋអាមេរិកដែលបានប្រព្រឹត្តទៅនៅរដ្ឋធានីវ៉ាស៊ីនតោន កាលពីពេលថ្មីៗកន្លងមកនេះ ដែលប្រធានអាស៊ានដឹកនាំដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងសហរដ្ឋអាមេរិក ក៏ជាសហប្រធាននៃជំនួបកំពូលនេះដែលប្រព្រឹត្តទៅប្រកបដោយលទ្ធផលជាផ្លែផ្កា រួមចំណែកដល់ការពង្រឹងនូវទំនាក់ទំនងកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខណ្ឌអាស៊ាន និងសហរដ្ឋអាមេរិក ក៏ដូចជាទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិកផងដែរ ។

**សម្តេចក្រឡាហោម** ក៏បានយកឱកាសនេះ ថ្លែងអំណរគុណចំពោះការជួយគាំទ្ររបស់សហរដ្ឋអាមេរិក មកលើដំណើរការអភិវឌ្ឍក៏ដូចជាដំណើរការស្វែងរកសុខសន្តិភាពរបស់កម្ពុជា នៅក្នុងរយៈពេលកន្លងមក ជាពិសេស គឺបេសកកម្ម



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះក៏មានការចូលរួមចំណែកជួយគាំទ្រពីសហរដ្ឋអាមេរិកផងដែរ ដែលលទ្ធផលនេះជាការស្តែងឲ្យឃើញនូវការចូលរួមរបស់សហរដ្ឋអាមេរិកក្នុងការជួយគាំទ្រដល់ប្រជាពលរដ្ឋកម្ពុជា នៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

ជាមួយគ្នានោះដែរ **សម្តេច** ក៏បានអបអរសាទរចំពោះវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការងារសន្តិសុខ ព្រមជាមួយនីតិវិធីអនុវត្តច្បាប់ និងមានក្តីសង្ឃឹមជឿជាក់ថាភាគីទាំងពីរនឹងបន្តពិនិត្យលទ្ធភាពក្នុងការពង្រីងពង្រីកកិច្ចសហប្រតិបត្តិការនេះបន្ថែមទៀត។

ជាការឆ្លើយតប ឯកឧត្តម ឧបការីរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការ អាស៊ីបូព៌ា ប៉ាស៊ីហ្វិក បានថ្លែងអំណរគុណ និងបង្ហាញការគាំទ្រចំពោះប្រសាសន៍លើកឡើងរបស់ **សម្តេចក្រឡាហោម** អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ។

ទន្ទឹមនេះ ឯកឧត្តម ក៏បានបង្ហាញនូវការចូលរួមអបអរសាទរចំពោះលទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានសហរដ្ឋអាមេរិកកាលពីពេលកន្លងទៅដែលកម្ពុជា ក្នុងនាមជាប្រធានអាស៊ាន និងសហរដ្ឋអាមេរិកក៏ជាសហប្រធាននៃជំនួបកំពូលនៅពេលនោះរួមទាំងថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ានផ្សេងទៀត ក៏បានជជែកពិភាក្សាផ្លាស់ប្តូរយោបល់ប្រកបដោយផ្លែផ្កា ។

**សម្តេចក្រឡាហោម** និង ឯកឧត្តម ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ក៏បានពិភាក្សាពាក់ព័ន្ធនឹងការផ្ញើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក និងបានផ្លាស់ប្តូរយោបល់គ្នាទៅលើកិច្ចសហប្រតិបត្តិការវិស័យអនុវត្តច្បាប់ដែលក្នុងនោះរួមមានកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រឆាំងការជួញដូរមនុស្ស និងការងារ ប្រយុទ្ធប្រឆាំងអំពើភេរវកម្មដោយភាគីទាំងពីរបានចាត់ទុកកិច្ចសហប្រតិបត្តិការនេះថាមានសារៈសំខាន់ដែលត្រូវតែបន្តពង្រឹង និងពង្រីក ពិសេសលើអ្វីដែលបានអនុវត្តកន្លងមករវាងភាគីទាំងពីរ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម អនុញ្ញាតិឲ្យក្រុមនិស្សិតជ័យលាភីអាហារូបករណ៍





នៅរសៀលថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឲ្យក្រុមនិស្សិតជ័យលាភីអាហារូបករណ៍ទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួងមហាផ្ទៃ ។

អញ្ជើញមានប្រសាសន៍ទៅកាន់ក្រុមនិស្សិតក្នុងពេលនោះ **សម្តេចក្រឡាហោម** បានសំដែងនូវការស្វាគមន៍ចំពោះក្រុមនិស្សិតជ័យលាភីអាហារូបករណ៍ទាំងអស់ និងមានមនោសញ្ចេតនាដែលបានទទួលជួបក្រុមនិស្សិត នាថ្ងៃនេះមុនពេលចេញទៅបន្តការសិក្សាយកចំណេះដឹង ។ **សម្តេច** មានក្តីសង្ឃឹមថា ការសិក្សារបស់ក្រុមនិស្សិតនៅប្រទេសជប៉ុន ពិតជាទទួលបានជោគជ័យ ដើម្បីយកចំណេះវិជ្ជាវិលត្រឡប់មកបម្រើការងារនៅមាតុប្រទេសវិញ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍សង្កត់ធ្ងន់ថា៖ អាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុននាពេលនេះជាលទ្ធផល កើតចេញពីការខិតខំប្រឹងប្រែងសិក្សារៀនសូត្រយ៉ាងខ្លាំងក្លារបស់ក្រុមនិស្សិត



៣កុំ ៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ទៅសិក្សានៅថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ នៅប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម



បង្ហាញឱ្យឃើញនូវការប្រែប្រួលថ្មីមួយទៀតចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន ព្រោះថានិស្សិតអាហារូបករណ៍ទាំងអស់ក៏អាចបង្កើតទំនាក់ទំនងថ្មីៗបន្ថែមទៀតជាមួយសាស្ត្រាចារ្យជប៉ុន និងបរទេស និស្សិតជប៉ុន និងនិស្សិតមកពីប្រទេសផ្សេងៗជាច្រើនទៀត ។

**សម្តេចក្រឡាហោម** បានមាន





ពោល គឺមិនមែននិស្សិតទូទៅសុទ្ធតែអាចទទួលបានអាហារូបករណ៍នេះ ដោយងាយៗនោះទេ... ហើយជាការលើកទឹកចិត្ត **សម្តេច** តែងតែស្វាគមន៍ និងទទួលជួបជាមួយ ក្រុមនិស្សិតអាហារូបករណ៍ជានិច្ច ដោយ**សម្តេចក្រឡាហោម** បានចាត់ទុកវត្តមានទៅសិក្សានៅប្រទេសជប៉ុនរបស់ក្រុមនិស្សិតទាំងអស់ថា គឺជាការរួមចំណែកប្រសាសន៍បន្ថែមទៀតថា៖ ជាការពិតក្នុងឱកាសទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុននេះ ក្រុមនិស្សិត

☞ ៤៨



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម អញ្ជើញជាអធិបតីក្នុងពិធី ប្រកាសចូលកាន់មុខតំណែងអភិបាល នៃគណៈអភិបាល ខេត្តព្រះវិហារ





នាព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសចូលកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។

តាមរយៈព្រះរាជក្រឹត្យលេខ **នស/រកត/០៧២២/៨១២** ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០២២ ត្រាស់បង្គាប់តែងតាំង ឯកឧត្តម **គីម រិទ្ធី** ជានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៣ ជាអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ។

អញ្ជើញសំណេះសំណាលក្នុងឱកាសនោះ **សម្តេចក្រឡាហោម** ក្នុងនាម **សម្តេចតេជោ** ប្រមុខរាជរដ្ឋាភិបាល បានមានប្រសាសន៍កោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះរដ្ឋបាលគ្រប់ថ្នាក់នៃ ខេត្ត



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




ព្រះវិហារ ក្រុមការងាររាជរដ្ឋាភិបាល មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋ ខេត្តព្រះវិហារ ដែលបានសហការគ្នាថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម សម្រេចបាននូវលទ្ធផលជាច្រើន រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។

**សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍កោតសរសើរផងដែរ ចំពោះការគ្រប់គ្រងសភាពការណ៍ក្នុងក្របខណ្ឌខេត្តទាំងមូលបានយ៉ាងល្អប្រសើរ ពិសេសការការពារសន្តិសុខសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើឱ្យមជ្ឈដ្ឋានជាតិ និងអន្តរជាតិ វាយតម្លៃជាទូទៅថាការបោះឆ្នោតនេះ បានប្រព្រឹត្តទៅប្រកបដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងស្របតាមច្បាប់ បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត ។

**សម្តេចក្រឡាហោម** បានសំដែងនូវក្តីសង្ឃឹមជឿជាក់ថា ៖ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តថ្មី នឹងប្រើប្រាស់សមត្ថភាព និងបទពិសោធន៍ដឹកនាំបន្តការអភិវឌ្ឍបន្ថែមទៀតនូវសមិទ្ធផល និងស្នាដៃនានា ដែលថ្នាក់ដឹកនាំខេត្តមុនៗ សម្រេចបាន ដើម្បីឱ្យ ខេត្តព្រះវិហារ កាន់តែមានការរីកចំរើន ។ ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានស្នើក្រុមប្រឹក្សាខេត្ត អភិបាលរង ថ្នាក់ដឹកនាំ មន្ទីរជុំវិញខេត្ត ថ្នាក់ដឹកនាំ

៤៧


ឯកឧត្តម **គីម រិទ្ធី** អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ




៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# វគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត ១ និងកម្រិត ២ ជំនាន់ទី ១ បានបញ្ចប់ដោយជោគជ័យ



ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ សេង ផល្លី ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា



នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត១ និងកម្រិត២ ជំនាន់ទី១ នៅបណ្ឌិត្យសភានគរបាលកម្ពុជា ស្ថិតនៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

នៅក្នុងរបាយការណ៍ស្វាគមន៍របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា បានបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត១ និងកម្រិត២ ជំនាន់ទី១នេះ ជាការអនុវត្តតាមកម្មវិធីកំណែទម្រង់ និងផែនការអភិវឌ្ឍធនធានមនុស្សក្រសួងមហាផ្ទៃ ពិសេសស្របតាមការយកចិត្តទុកដាក់ពី **សម្តេចក្រឡាហោម** ចំពោះថ្នាក់ដឹកនាំនគរបាលដែលមិនទាន់បានឆ្លងកាត់វគ្គ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

សិក្សាទាក់ទងនឹងជំនាញនគរបាល។ **ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ** បានបញ្ជាក់ឱ្យដឹងទៀតថា៖ សិក្ខាកាមទាំង២វគ្គនេះ ត្រូវបានចាត់បញ្ជូនមកពីអគ្គនាយកដ្ឋាន-អង្គភាព និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សរុបចំនួន១១៩

ឱ្យមាន**អត្តចរិកល្អ អាកប្បកិរិយា ស្មោះត្រង់ ភ្លាមៗ មុះមុត គោរពវិន័យច្បាប់ ឋានានុក្រម** ការចេះធ្វើការងារជាក្រុម និងការងារទំនាក់ទំនងជាអន្តរបុគ្គល ។

ឱកាសនោះដែរ ក្នុងពិធីនោះ **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងនាម **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងនូវការកោតសរសើរ និងអរគុណបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយក

៤៣





នាក់ ស្រី២នាក់ ។ វគ្គបណ្តុះបណ្តាលនេះ បានតម្រង់ទិសសិក្ខាកាមឱ្យទទួលបានចំណេះដឹង និងជំនាញវិជ្ជាជីវៈក្នុងការបំពេញតួនាទីជាថ្នាក់ដឹកនាំទាំងលើជំនាញ **ដឹកនាំ បញ្ជា សន្តិសុខ គ្រប់គ្រងកងកម្លាំង ផ្លែងសុន្ទរកថា ដឹកនាំកិច្ចប្រជុំ ធ្វើជំនួយស្មារតី ការងារពិធីការ ការគោរពគំនាប់ និងរបៀបបំពេញការងារ** និងការរស់





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម អនុញ្ញាតឲ្យអនុរដ្ឋមន្ត្រីក្រសួង យុត្តិធម៌ ជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



នៅរសៀលថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឲ្យ ឯកឧត្តម Ga Da (**កា ដា**) អនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមានរដ្ឋសភា ។

ក្នុងជំនួបនោះ ឯកឧត្តម Ga Da (**កា ដា**) បានថ្លែងអំណរគុណជូន **សម្តេចក្រឡាហោម** ដែលបានចំណាយពេលវេលាទទួលជួបឯកឧត្តម និងបានយកឱកាសនេះជម្រាបជូន **សម្តេចក្រឡាហោម** នូវសេចក្តីថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលបានចូលរួមរំលែកមរណទុក្ខចំពោះមរណភាព ឯកឧត្តម Shinzo Abe (**ស៊ិន ហ្សូអាបេ**) អតីតនាយករដ្ឋមន្ត្រីជប៉ុន ។

ឯកឧត្តម Ga Da (**កា ដា**) បានជម្រាបជូន **សម្តេចក្រឡាហោម** ថាក្រសួងយុត្តិធម៌ជប៉ុន កំពុងរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជប៉ុន-អាស៊ាន



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ដែលគ្រោងធ្វើឡើងនៅឆ្នាំ២០២៣ និងជាកិច្ចប្រជុំលើកទី១ ដែលអាស៊ានមានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយប្រទេសក្រៅពីសមាជិកអាស៊ាន ។

ឯកឧត្តម បានមានប្រសាសន៍ទៀតថា៖ ការចែករំលែកតម្លៃជាសកល ដូចជានីតិរដ្ឋ និងសិទ្ធិមនុស្ស មានសារៈសំខាន់សម្រាប់សហគមន៍អន្តរជាតិ ក្នុងនោះកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ ក៏មានសារៈសំខាន់ក្នុងការលើកកម្ពស់ការចែករំលែកគុណតម្លៃជាសកលនេះ ។ ដូច្នេះកិច្ចប្រជុំនេះត្រូវការចែករំលែកជាសាកលក្នុងអាស៊ានរួមទាំងកម្ពុជាផងដែរ ដោយសង្ឃឹមទទួលបានការគាំទ្រពីកម្ពុជាចំពោះបញ្ហានេះ ។

ឯកឧត្តម បានជម្រាបជូន **សម្តេចក្រឡាហោម** អំពីវិស័យពន្ធនាគារដោយបានបញ្ជាក់ថាអង្គការសហប្រជាជាតិសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តចំពោះជនល្មើស ហៅកាត់ថា UNAFEI កំពុងសហការរៀបចំសិក្ខាសាលាមួយនៅប្រទេសជប៉ុន ដើម្បីជំរុញការអភិវឌ្ឍ និងការផ្លាស់ប្តូរឆនឆាន ការកសាងបណ្តាញក្នុងវិស័យច្បាប់ និងយុត្តិធម៌ដែលបញ្ហានេះ ឯកឧត្តម សង្ឃឹមថាក្រសួងមហាផ្ទៃ នឹងចាត់មន្ត្រីចូលរួម ។

ពាក់ព័ន្ធនឹងការងារអន្តោប្រវេសន៍ស្ថិតក្រោមសមត្ថកិច្ចក្រសួងយុត្តិធម៌ជប៉ុនដែរនោះ ឯកឧត្តម Ga Da( **គា ដា** ) បានជម្រាបជូន **សម្តេច** ថាក្រសួងយុត្តិធម៌ជប៉ុន ក៏បានរៀបចំវេទិកាអន្តោប្រវេសន៍ភូមិភាគ ដោយមានការចូលរួមផ្លាស់ប្តូរព័ត៌មានពីបណ្តាប្រទេសអន្តរជាតិនានា ដែលបញ្ហានេះ ឯកឧត្តម បានថ្លែងអំណរគុណរាជរដ្ឋាភិបាលកម្ពុជា ដែលបានបញ្ជូនមន្ត្រីចូលរួមវេទិកាកន្លងមកនេះ ខណៈការរៀបចំលើកទី២នឹងធ្វើឡើងនៅចុងឆ្នាំនេះ ជាមួយក្តីរំពឹងថារាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបញ្ជូនមន្ត្រីទៅចូលរួម ។

មានប្រសាសន៍ឆ្លើយតបវិញ៖ **សម្តេចក្រឡាហោម** បានសំដែងនូវការស្វាគមន៍ឯកឧត្តម Ga Da ( **គា ដា**) រួមទាំងប្រតិភូសម្រាប់ដំណើរទស្សនកិច្ចនៅកម្ពុជា និងបានសម្តែងក្តីសង្ឃឹមថាកិច្ចសហប្រតិប្រតិបត្តិការក្នុងវិស័យច្បាប់រវាងកម្ពុជានិងជប៉ុននឹងកាន់តែរីកចម្រើន ។

៤៤



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម អញ្ជើញពិនិត្យវឌ្ឍនភាព





កាលពីរសៀលថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ កន្លងមកនេះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃទីស្តីការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ ឯកឧត្តម អគ្គនាយក អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ឯកឧត្តម អស់លោក លោកស្រី ជាមន្ត្រី





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# នៃដំណើរការ សាងសង់អគារថ្មី ទីស្តីការ ក្រសួងមហាផ្ទៃ



ឧត្តមសេនីយ៍ឯក **ប៊ិន មណីរដ្ឋ** ប្រធាននាយកដ្ឋានស្ថាបនា និងវិស្វកម្ម នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងជាសមាជិកក្រុមការងារបច្ចេកទេសសាងសង់





ជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងតំណាងក្រុមហ៊ុនសាងសង់ជាច្រើនរូបទៀត ។

**គួរបញ្ជាក់ផងដែរថា**ៈ អគារថ្មីនៃទីស្តីការក្រសួងមហាផ្ទៃ បានប្រារព្ធពិធីបញ្ចុះបឋមសិលា កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** និង លោកជំទាវ ។

អគារថ្មីនេះ មានទំហំ១៥៣ ម៉ែត្រ គុណ ៨៣ម៉ែត្រ មានកម្ពស់ ៩ជាន់ ដោយមិនរាប់បញ្ចូលជាន់ផ្ទាល់ដី និងជាន់សម្រាប់ចំណតរថយន្ត ចំនួន ៣៣០ គ្រឿង ។

អគារនេះមានមុខងារប្រើប្រាស់ជាលក្ខណៈ អគាររដ្ឋបាលប្រមូលផ្តុំ ថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អង្គភាពឋានៈស្មើរចំនួន១២ គណៈកម្មាធិការជាតិចំនួន៥ គណៈកម្មការក្រសួងមហាផ្ទៃចំនួន៦ លេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងនាយកដ្ឋានជំនាញចំនួន៤២ ដែលអាចផ្ទុកមនុស្សសរុបរហូតដល់ទៅ ៨.៥០០នាក់ ។

**គួរបញ្ជាក់ផងដែរថា** ៖ តាមការបញ្ជាក់ឱ្យដឹងពី ឧត្តមសេនីយ៍ឯក **ប៊ិន មណីរដ្ឋ** ប្រធាននាយកដ្ឋានស្ថាបនា និងវិស្វកម្ម

☞ ៤១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឆមាសទី១ ឆ្នាំ ២០២២ ក្នុងចំណោមអ្នកជិះម៉ូតូ ដែលរងគ្រោះថ្នាក់ចរាចរណ៍ដល់ស្លាប់ចំនួន ៨១ភាគរយ មាន ៧៤ភាគរយ មិនពាក់មួកសុវត្ថិភាព






នាព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក **គ.ស.ច.គ** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២២ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ សមាជិក សមាជិកានៃ **គ.ស.ច.គ** អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត នាទីស្តីការក្រសួងសាធារណៈការ និងដឹកជញ្ជូន ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ក្នុងរបាយការណ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២២ ដែលអានដោយ លោកជំទាវ **មីន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ច.គ** បានបញ្ជាក់ថា៖ គ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងក្នុង ឆមាសទី១ ឆ្នាំ២០២២ មានចំនួន




ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ស.ច.គ



១.៦០៩លើក បណ្តាលឱ្យស្លាប់ ៩៤៧ នាក់ និងរបួស២.២៣៥នាក់ ធ្ងន់ចំនួន ១.៤២៩នាក់ ។ ចំពោះមូលហេតុគ្រោះថ្នាក់រួមមានល្បឿនលឿន ៣៨% បើកបរមិនគោរពសិទ្ធិ ២៤% មិនប្រកាន់ស្តាំ ១១% វ៉ាដែង១១% បត់១០% ស្រវឹង ៣% កត្តាយានយន្ត២% និងងងុយ ១%ក្នុងចំណោមអ្នកស្លាប់ជាអ្នកជិះម៉ូតូចំនួន ៨១% (៧៥៥/៩៤៧នាក់) មានអ្នកមិនពាក់មួកសុវត្ថិភាពចំនួន៧៤%( ៥៥៨/៧៥៥ នាក់ )។

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍ **គ.ស.ច.គ** បានឯកភាពលើរបាយការណ៍ដែលបានលើកឡើង ព្រមទាំងអបអរសាទរផងដែរចំពោះបទអន្តរាគមន៍របស់រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តព្រះសីហនុ ។ ដោយឡែកចំពោះទិសដៅការងារសម្រាប់អនុវត្តឆមាសទី២ ក្នុងឆ្នាំ២០២២ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក្នុងនាមអនុប្រធានអចិន្ត្រៃយ៍ **គ.ស.ច.គ** នឹងបន្តជំរុញយុទ្ធនាការអប់រំផ្សព្វផ្សាយអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៅតាមរាជធានី-ខេត្តទាំង២៥ ព្រមទាំងទិញចែកស្ទីកឃ័រចំណាំងផ្លាត និងមួកសុវត្ថិភាពដល់អ្នកបើកបរទោចក្រយានយន្តទូទាំងប្រទេស ។

អញ្ជើញមានប្រសាសន៍ក្នុងឱកាសនោះ **សម្តេចក្រឡាហោម** ប្រធាន **គ.ស.ច.គ** បានសម្តែងនូវការកោតសរសើរដល់កងកម្លាំងចរាចរណ៍ផ្លូវគោក មន្ត្រីនៃក្រសួងសាធារណការ និងដឹកជញ្ជូន កងរាជអាវុធហត្ថ មន្ត្រីគុណាការ មន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងបងប្អូនប្រជាពលរដ្ឋដែលបានខិតខំយ៉ាងសកម្មក្នុងការបំពេញកិច្ចការសុវត្ថិភាពចរាចរណ៍ផ្លូវគោកនិងចូលរួមគោរពប្រតិបត្តិច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ធ្វើឱ្យការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រេចបានលទ្ធផលល្អប្រសើរតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងផែនការទស្សវត្សសុវត្ថិភាពចរាចរណ៍ផ្លូវគោក **គ.ស.ច.គ** ។

ក្នុងនោះផងដែរ **សម្តេចក្រឡាហោម** បានសំដែងនូវការកោតសរសើរចំពោះសកម្មភាពកសាងសមិទ្ធផលផ្លូវថ្នល់ ការសាងសង់ផ្លូវល្បឿនលឿន ផ្លូវឯកទិស ផ្លូវជនបទ ការជួសជុលនិងកែលម្អផ្លូវជាតិ ផ្លូវរាជធានី-ខេត្ត បម្រើដល់ការចរាចរណ៍កាន់តែមានសុវត្ថិភាព និងបម្រើដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យកាន់តែមានការរីកចម្រើនថែមទៀត ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានសំដែងនូវក្តីសង្ឃឹមយ៉ាងមុតមាំថា៖ ឈរលើស្មារតី បទពិសោធន៍ និងកិច្ចខិតខំប្រឹងប្រែងទទួលខុសត្រូវពីគ្រប់ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរគ្រប់លំដាប់ថ្នាក់ យើងនឹងអាចសម្រេចបានជោគជ័យក្នុងការបង្ការ ទប់ស្កាត់ ព្រមទាំងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ក្នុងឆមាសទី២ ឆ្នាំ២០២២ ក៏ដូចជាការរក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកឱ្យកាន់តែមានសុវត្ថិភាពល្អប្រសើរជាលំដាប់ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# បណ្ឌិត្យសភានគរបាលកម្ពុជា បើកវគ្គ
# សុក្រឹត្យការថ្នាក់ដឹកនាំ នគរបាលកម្រិត១ និងកម្រិត២ ជំនាន់ទី ២






នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ នៅបណ្ឌិត្យសភានគរបាលកម្ពុជា ឯកឧត្តម សន្តិបណ្ឌិត **ចាន់ អ៊ាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកវគ្គ**សុក្រឹត្យការថ្នាក់ដឹកនាំ**នគរបាលកម្រិត១ និងកម្រិត២ ជំនាន់ទី២ ដែលមានសិក្ខាកាម សរុបចំនួន **១៨០**នាក់ ស្រី **១៦**នាក់ នៅបណ្ឌិត្យសភានគរបាលកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា បានមានប្រសាសន៍បញ្ជាក់អំពីសារៈសំខាន់ និងគោលបំណងនៃវគ្គសិក្សាសម្រាប់សិក្ខាកាមទាំងអស់ដែលជាធនធានមនុស្សប្រកបដោយសក្ដានុពល និងមានប្រយោជន៍សម្រាប់ក្រសួងមហាផ្ទៃ ។ លើសពីនេះទៀត ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ ក៏បានមានប្រសាសន៍បញ្ជាក់ផងដែរថា៖ វគ្គសិក្សានេះមានគោលបំណងតម្រង់ទិសឱ្យសិក្ខាកាម



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ទទួលបានចំណេះដឹង បទពិសោធន៍ និងជំនាញវិជ្ជាជីវៈនគរបាលក្នុងការបំពេញតួនាទីជាថ្នាក់ដឹកនាំនគរបាលបានល្អ បន្ថែមលើជំនាញដែលមានស្រាប់ ។

មានប្រសាសន៍សំណេះសំណាលក្នុងឱកាសនោះ **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការ** បានគូសបញ្ជាក់ថា៖ ការបើកវគ្គសិក្សានេះ គឺជាការអនុវត្តតាមផែនការអភិវឌ្ឍន៍ធនធានមនុស្សផ្នែកកងកម្លាំងនគរបាលជាតិរបស់ក្រសួងមហាផ្ទៃ និងមតិដឹកនាំបញ្ជាផ្ទាល់របស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ស្របតាមគោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

**ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការ** បានមានប្រសាសន៍បញ្ជាក់ទៀតថា៖



ឯកឧត្តម សន្តិបណ្ឌិត ចាន់ ស៊ិន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ



ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ សេង ផល្លី ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា



ក្រសួងមហាផ្ទៃ បានបន្តធ្វើកំណែទម្រង់កងកម្លាំងនគរបាលជាតិ តាមរយៈការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈសុវត្ថិភាពសង្គម ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ។ មិនតែប៉ុណ្ណោះ ការងារបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិ គឺជាការងារចាំបាច់ ដែលត្រូវតែបន្តធ្វើជាប់ជាប្រចាំដោយគ្មានទីបញ្ចប់នោះទេ ក្នុងគោលដៅធ្វើទំនើបកម្មនៃចំណេះដឹង និងសមត្ថភាពជំនាញវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការនៃអង្គភាពប្រើប្រាស់កងកម្លាំង ព្រមទាំងសភាពការណ៍សន្តិសុខជាតិ និងអន្តរជាតិក្នុងចរន្តសាកលភាវូបនីយកម្ម ។

ជាចុងក្រោយ **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការ** បានផ្តល់អនុសាសន៍ មួយចំនួនដល់សិក្ខាកាមទាំងអស់ត្រូវយកចិត្តទុកដាក់សិក្សារៀនសូត្រ ហ្វឹកហាត់ ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ និងគោរពវិន័យឱ្យបានខ្ជាប់ខ្ជួនទៅតាមបទបញ្ជាផ្ទៃក្នុងរបស់បណ្ឌិត្យសភានគរបាលកម្ពុជាដែលបានកំណត់ ដើម្បីទទួលបានជោគជ័យក្នុងការសិក្សា ព្រមទាំងចូលរួមលើកកម្ពស់វប្បធម៌ គុណភាពផងដែរ ពោលគឺសិក្ខាកាមម្នាក់ៗត្រូវរៀនឱ្យចេះមិនមែនរៀនឱ្យចប់នោះទេ ។

**គួរបញ្ជាក់ដែរថា៖** វគ្គសុក្រឹត្យការថ្នាក់ដឹកនាំនគរបាលកម្រិត១ និង កម្រិត២ ជំនាន់ទី២នេះ ត្រូវបានបែងចែកពេលវេលាសិក្សាផ្សេងគ្នា ដោយកម្រិត១សិក្សាតែពេលព្រឹក មានរយៈពេល៤ខែ និងកម្រិត២សិក្សាមួយថ្ងៃពេញមានរយៈពេល៣ខែ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:01 AM

# ក្រសួងមហាផ្ទៃ និងអង្គការ IJM ចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាសម្រាប់កិច្ចសហប្រតិបត្តិការ ៣ឆ្នាំ បន្តទៀត




នៅព្រឹកថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២កន្លងមកនេះ ឯកឧត្តម សន្តិបណ្ឌិត **តេជ សាវឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងលោក **ចាកូប ស៊ីម** (Jacob Sims) នាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងក្រសួងមហាផ្ទៃ និងអង្គការ IJM សម្រាប់កិច្ចសហប្រតិបត្តិការរយៈពេល ៣ឆ្នាំបន្តទៀត ។





នាឱកាសនោះ **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការ** បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅ និងបានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គការ IJM ដែលបានផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/xzzk/




ឯកឧត្តម សន្តិបណ្ឌិត តេង សាវង្ស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងជាពិសេសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលជាអង្គភាពធ្វើប្រតិបត្តិការផ្ទាល់ជាមួយអង្គការ IJM លើសកម្មភាពការងារដែលបានកំណត់នៅក្នុងវិសាលភាពនៃ MOU ។







**ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** បានសម្តែងនូវក្តីសង្ឃឹមជឿជាក់ថា៖ តាមរយៈស្មារតីនៃអនុស្សរណៈដែលត្រូវបានចុះហត្ថលេខានាពេលនេះនឹងរួមចំណែកកាន់តែសកម្មថែមទៀត ក្នុងការបង្កលក្ខខណ្ឌកាន់តែប្រសើរឡើង សម្រាប់ភាគីទាំងពីរក្នុងការបន្តភារកិច្ច និងបេសកកម្មរួមគ្នា ដើម្បីលុបបំបាត់បទល្មើសជួញដូរមនុស្ស ក្នុងគោលដៅលើកកម្ពស់សេចក្តីថ្លៃថ្នូរ សិទ្ធិសេរីភាព សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល រៀបចំសន្និសីទសារព័ត៌មាន ឆ្លើយតបចំពោះរបាយការណ៍ ស្តីពីការជួញដូរមនុស្សលើពិភពលោក របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក



លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស( **គ.ជ.ប.ជ** )





កាលពីព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា បានរៀបចំសន្និសីទសារព័ត៌មានស្តីអំពី « **ស្ថានភាពនៃការជួញដូរមនុស្ស**» នៅកម្ពុជាក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស( **គ.ជ.ប.ជ**) ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម **កែវ សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ឯកឧត្តម **ហ៊ូ ខុឡារី** រដ្ឋលេខាធិការក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងមានវាគ្មិនជាច្រើនរូបទៀត ។

***លោកជំទាវ*** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃ **គ.ជ.ប.ជ** បានមានប្រសាសន៍បញ្ជាក់ថា៖ សន្និសីទសារព័ត៌មាន ពេលនេះមានគោល



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




បំណងពន្យល់ឆ្លើយតបឱ្យទាន់សភាពការណ៍ដែលសហរដ្ឋអាមេរិក បានសរសេរក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពី ការជួញដូរមនុស្សនៅលើពិភពលោករបស់ក្រសួងការបរទេសអាមេរិក ដែលដាក់កម្ពុជាក្នុង**ចំណាត់ថ្នាក់លេខ៣** ស្មើនឹងកម្ពុជាមិនបានធ្វើអ្វីសោះដែលជារឿងមិនពិតជាហេតុផលនៃការដាក់ទណ្ឌកម្មថែមទៀតគឺជារឿងអយុត្តិធម៌មិនអាចទទួលយកបានព្រោះកន្លងមករាជរដ្ឋាភិបាល ដៃគូជាតិ និងអន្តរជាតិបានដឹងច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទទួលលទ្ធផលជាច្រើន ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាល ក៏ដូចជាដៃគូសហការទាំងអស់ជាពិសេសអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ បាននិងកំពុងខិតខំប្រឹងប្រែងរិះរកគ្រប់វិធានការក្នុងន័យរួមគ្នាដោះស្រាយលើបញ្ហានេះ ឈានទៅសម្រេចបាននូវការលុបបំបាត់នូវអំពើជួញដូរមនុស្ស ព្រមទាំងបានរៀបចំនូវយន្តការការពារទៅលើប្រជាពលរដ្ឋទូទៅ ពលករ ធុរកិច្ចជន ភ្ញៀវជាតិ និងអន្តរជាតិគ្រប់និន្នាការទាំងអស់ ដោយមិនប្រកាន់នូវជាតិ សាសនាអ្វីទាំងអស់ សំដៅប្រែក្លាយទៅជាប្រទេសដែលមានសុខសុវត្ថិភាព ។

លើសពីនេះទៀតរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងកែប្រែទៅលើយន្តការជាតិជាបន្តបន្ទាប់ ដើម្បីជាការឆ្លើយតបទៅនឹងការវិវត្តនៃកលល្បិចរបស់ឧក្រិដ្ឋជនដែលយន្តការជាតិនេះ មានលក្ខណៈទូលំទូលាយ ។ ជាក់ស្តែងក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស( **គ.ជ.ប.ជ**) ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន២២និងមានអង្គភាពជំនាញសំខាន់ៗចំនួន៥ បានចូលរួម រួមទាំងមានអង្គការក្រៅរដ្ឋាភិបាលជាដៃគូរផងដែរ ។

***លោកជំទាវ*** អនុប្រធានអចិន្ត្រៃយ៍ **គ.ជ.ប.ជ** បានមានប្រសាសន៍បញ្ជាក់ក្នុងសន្និសីទសារព័ត៌មាននេះ បន្ថែមទៀតថា៖ អំពើជួញដូរមនុស្ស ងាយកើតឡើងទៅលើប្រជាពលរដ្ឋដែលបានធ្វើទេសន្តរប្រវេសន៍ទៅក្រៅប្រទេស ដោយពុំមានឯកសារផ្លូវច្បាប់គ្រប់គ្រាន់ គឺងាយនឹងទទួលរងនូវការកេងប្រវ័ញ្ច ធ្វើបាបគៀបសង្កត់ ។ នៅក្នុងឆ្នាំ២០២១ការបង្ក្រាបបទល្មើសបានចំនួន៣៥៩ករណី សង្គ្រោះប្រជាពលរដ្ឋបានចំនួន ១៥៧៧នាក់ បានបញ្ជូនទៅតុលាការចំនួន ៥៣៨ករណី ដែលចំនួននេះមានការកើនឡើងបើធៀបនឹងឆ្នាំ២០១៩ គឺមានត្រឹម១៥៥ករណី សង្គ្រោះប្រជាជនបានចំនួន ៤៦៧នាក់ ប៉ុណ្ណោះ ។ **គ.ជ.ប.ជ** បានខិតខំប្រឹងប្រែងប្រយុទ្ធនឹងបញ្ហានេះ ដោយខិតខំបង្កើនការចុះអប់រំផ្សព្វផ្សាយ នៅតាមបណ្តាមូលដ្ឋានមានចំនួន១២ម៉ឺនលើក ព្រមទាំងបាននិងកំពុងរៀបចំនូវផែនការប្រតិបត្តិការពិសេសសម្រាប់ស្រាវជ្រាវ និងបង្ក្រាបទៅលើករណីជួញដូរមនុស្ស ដែលមានលើទឹកដីកម្ពុជាផងដែរ ។

ជាក់ស្តែងតាមរយៈកិច្ចសហប្រតិបត្តិការកន្លងមករវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូសហការទាំងថ្នាក់ក្រោមជាតិ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលទាំងអស់ **គ.ជ.ប.ជ**មានសង្ឃឹមយ៉ាងមុតមាំថា កម្ពុជានឹងទទួលបានលទ្ធផលល្អប្រសើរក្នុងការបង្ក្រាប ទប់ស្កាត់ និងឈានទៅលុបបំបាត់អំពើនេះ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន
## រដ្ឋមន្ត្រីក្រសួងការបរទេសនិង



កាលពីព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានទទួលជួបស្វាគមន៍ និងពិភាក្សាការងារជាមួយ លោកជំទាវ **រ៉េតណូ អិល ភី ម៉ាស៊ូឌី** ( RETNO L.P MARSUDI ) រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ក្នុងជំនួបពិភាក្សាការងារនេះ ភាគីឥណ្ឌូណេស៊ី បានថ្លែងអំណរគុណដល់កងកម្លាំងនគរបាលជាតិកម្ពុជា ដែលបានខិតខំប្រឹងប្រែងជួយសង្គ្រោះពលរដ្ឋឥណ្ឌូណេស៊ីរងគ្រោះនៅក្នុងប្រទេសកម្ពុជា ។ ក្រៅពីនេះភាគីទាំងពីរ ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់ និងឯកភាពគ្នាលើការងារសំខាន់មួយចំនួនទៀត ដើម្បីបន្តអនុវត្ត គឺការជួយគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរគ្រប់ប្រភេទ ជាពិសេសបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យា និងជំរុញកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធ និងស៊ីជម្រៅ ដោយបង្កើតយន្តការផ្លាស់ប្តូរព័ត៌មាន បម្រើឲ្យការស៊ើបអង្កេត ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ការបង្កើតឲ្យមានមន្ត្រីបង្គោល ដើម្បីផ្តល់ព័ត៌មាន និងគំនិតផ្តួចផ្តើមបង្កើតអនុស្សរណៈយោគយល់គ្នា ( MOU ) ដែលជាមូលដ្ឋានសម្រាប់បម្រើឲ្យការចាត់តាំងអនុវត្ត និងគាំទ្រឲ្យក្រុមបច្ចេកទេសកងកម្លាំងនគរបាលជាតិនៃប្រទេសទាំងពីររួមគ្នាដើម្បីស្វែងរកវិធីសាស្ត្រ និងយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ និងលុបបំបាត់ឲ្យអស់ឬសគល់នៃបណ្តាញ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:01 AM




# ទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ
# សហប្រតិបត្តិការអន្តរជាតិ ឥណ្ឌូនេស៊ី



ឲ្យកិច្ចដូនដូញដូរមនុស្សទាំងនៅឥណ្ឌូណេស៊ី និងនៅប្រទេសកម្ពុជា ។

ក្នុងឱកាសនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ក៏បានរំលឹករំពីគុណបំណាច់របស់កងទ័ពឥណ្ឌូណេស៊ីក្នុងបេសកកម្មស្វែងរកសន្តិភាពជូនប្រទេសកម្ពុជាក្នុងទសវត្សទី៩០ ផងដែរ ៕







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/xzzk/




# សម្តេចក្រឡាហោម « មកជួយឲ្យល្អ



ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សាសាលាបឋមសិក្សា **ហ៊ុន សែន ថ្កូល់ទទឹង** សាលារៀនខ្មែរ-ចិន **ចេង ម៉េង** និងសមិទ្ធផលនានា ស្ថិតនៅភូមិថ្កូល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ។





៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:01 AM



# តែបើធ្វើមិនបានល្អ អាញ៉ឹងអ្នកឯងនឹងអាក្រក់ដែរ »







ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល បានបញ្ជាក់ថា៖ អគារសិក្សាសាលាបឋមសិក្សា **ហ៊ុន សែន ថ្មល់ទទឹង** និងអគារសិក្សាសាលារៀនខ្មែរ-ចិន **ចេង ម៉េង** ព្រមទាំងសមិទ្ធផលនានាជាច្រើនទៀត រួមមាន ផ្លូវបេតុងអាមេ ការចាក់សាប ចាក់ដី ដាំកូនឈើ ធ្វើសួនច្បារ និងឧបករណ៍កីឡាផ្សេងៗ ដែលសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលនេះ

☞ ២៧



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/xzzk/











តមកពីទំព័រ ២៦

**សម្តេចក្រឡាហោម ស ខេង មកជួយឲ្យល្អ...**

មានដូចជា នៅសាលាបឋមសិក្សា **ជួលទទឹង** ក្នុងឆ្នាំ២០១៩ មានអគារចំនួន ១ខ្នង ពីរជាន់ ស្មើនឹង១២បន្ទប់ និងនៅសាលារៀន ខ្មែរ-ចិន **ចេង ម៉េង** អគារសិក្សា១ខ្នង កំពស់២ជាន់ មាន៦បន្ទប់ និងអគារផ្ទាល់ដី ៣ខ្នង ស្មើ១៤បន្ទប់ ដែលបានផ្តួចផ្តើមឧបត្ថម្ភការកសាងដោយ លោក **ឧកញ៉ា តែ អ៊ីឆែ** និង**ភរិយា** ។

អញ្ជើញមានប្រសាសន៍នាឱកាសនោះ **សម្តេចក្រឡាហោម** ក្នុងនាម **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងអំណរគុណ និងកោតសរសើរចំពោះ លោក**ឧកញ៉ា តែ អ៊ីឆែ** និង**ភរិយា** ព្រមទាំងក្រុមគ្រួសារ និងសប្បុរសជនទាំងអស់ដែលបានចូលរួមសាមគ្គីបរិច្ចាកថវិកាគាំទ្រដំណើរការកសាងអគារសិក្សាដែលជាផ្នែកមួយដ៏មានសារៈសំខាន់នៅក្នុងដំណើរការបណ្តុះបណ្តាល និងកសាងធនធានមនុស្សនៅកម្ពុជា ។

ឆ្លៀតក្នុងពិធីនោះ **សម្តេចក្រឡាហោម** ក៏បានថ្លែងអំណរគុណប្រជាពលរដ្ឋ និងអាជ្ញាធរ កងកម្លាំងទាំងអស់នៅតាមមូលដ្ឋាន ដែលបានចូលរួមគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឱ្យប្រព្រឹត្តទៅប្រកបដោយភាពរលូននិងគ្មានអំពើហិង្សា ។ **សម្តេច** បញ្ជាក់ថា « **យើងទាំងអស់គ្នាមានភាពចាស់ទុំខាងនយោបាយ នេះជាមោទនភាពធំណាស់ និងជាទុនធំណាស់សម្រាប់ប្រទេសជាតិយើង សម្រាប់អនាគតកូនចៅយើងដែលយើងត្រូវតែពង្រីកវាបន្ថែមទៀត ដោយជៀសវាងជម្លោះនៅ**



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









ពេលបោះឆ្នោត » ។

ពាក់ព័ន្ធអំពីបញ្ហាគ្រឿងញៀន នៅកម្ពុជា ដែលពេលនេះកំពុងប្រឈម នឹងកំណើនគ្រឿងញៀនចេញពីការកែច្នៃ ដោយសមាសធាតុគីមីផ្សេងៗ **សម្តេចក្រឡាហោម** បានបញ្ជាក់អំពីការទទួល បានការអនុញ្ញាតពី **សម្តេចតេជោ** រៀបចំ សេចក្តីព្រាងច្បាប់មួយដើម្បីគ្រប់គ្រង ការនាំចូលសារធាតុគីមី និងទប់ស្កាត់កុំ ឱ្យមានការបង្វែរយកទៅផលិតជាគ្រឿង ញៀន ព្រោះថាបញ្ហាគ្រឿងញៀននេះក៏ មានការជាប់ពាក់ព័ន្ធផងដែរនឹងបទល្មើស សម្អាតប្រាក់ អំពើភេរវកម្ម និងការរីក សាយភាយអាវុធមហាប្រល័យ ។

ដោយឡែកពាក់ព័ន្ធនឹងការប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស **សម្តេចក្រឡាហោម** បានបង្ហាញការភ្ញាក់ផ្អើលចំពោះ ការសម្រេចរបស់រដ្ឋាភិបាលអាមេរិក ក្នុងការដាក់កម្ពុជា ក្នុងចំណាត់ថ្នាក់លេខ៣ ដែលមានន័យថារាជរដ្ឋាភិបាលកម្ពុជា គ្មានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស ។

**សម្តេច** មានប្រសាសន៍បញ្ជាក់ថា « *ខ្ញុំក៏បារម្ភឬក៏ថាមានការភ្ញាក់ផ្អើលដែរ ព្រោះខ្ញុំក្នុងឋានៈជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែងសហការជាមួយដៃគូអន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិកតែម្តង ប៉ុន្តែខ្ញុំមានការបារម្ភ ពើលក្នុងឆ្នាំនៃការវាយតម្លៃ ឬមួយនាសម័យកាលនៃការវាយតម្លៃ ប៉ុន្តែទោះបី យ៉ាងណាក៏ដោយកម្ពុជា នៅតែមានឆន្ទៈ និងនៅតែបន្តធ្វើការងារនេះ ហើយនៅតែបន្តសម្រេចកិច្ចសហប្រតិបត្តិការជាមួយដៃគូទាំងអស់ដោយស្មោះជាមួយគ្នា* ។ **សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់បន្ថែមទៀតថា៖ *យើងនិយាយតាមរបៀបសាមញ្ញថា អ្នកមកជួយខ្ញុំដើម្បីជួយឱ្យខ្ញុំឈ្នះ តែបើខ្ញុំចាញ់មានន័យថាអ្នកឯងក៏ចាញ់ដែរ មិនមែនចាញ់តែខ្ញុំទេ...មកជួយឱ្យល្អ តែបើធ្វើមិនបានល្អអាហ្នឹងអ្នកឯងក៏អាក្រក់ដែរ* » ។៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម អញ្ជើញដឹកនាំ
## បោសសម្អាត គ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ




នៅទីស្តីការក្រសួងមហាផ្ទៃ ព្រឹកថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យវឌ្ឍនភាពកិច្ចប្រតិបត្តិការបោសសម្អាតគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះក្រោមទឹក និងស្រង់នាវាលិចក្នុងបាតទន្លេ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ស៊ុយ សែម**





រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ និងជាប្រធានក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សា និងដោះស្រាយករណីឃើញគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះក្នុងនាវាលិចក្នុងទន្លេ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ ឯកឧត្តម **ហេង រតនា** ប្រតិភូរាជរដ្ឋាភិបាលទទួល



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:01 AM

# កិច្ចប្រជុំពិនិត្យវឌ្ឍនភាពកិច្ចប្រតិបត្តិការ ក្រោមទឹក និង ស្រង់នាវាលិច ក្នុងបាតទន្លេ







បន្ទុកអគ្គនាយកស៊ីម៉ាក់(CMAC) ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត ។

ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការប្រចាំការក្រសួងការពារជាតិ បានធ្វើរបាយការណ៍ឱ្យដឹងថា៖ គិតមកដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២នេះ ក្រុមការងារបានស្រង់គ្រាប់យុទ្ធភណ្ឌក្រោមទឹកបានជាង១ពាន់គ្រាប់ហើយ ស្មើនឹងជាង ១៧តោន ។ ទន្ទឹមគ្នានេះ មន្ត្រីក្រុមការងារទាំងអស់បានខិតខំពុះពាររាល់ការលំបាក និងហ៊ានពលិកម្មគ្រប់បែបយ៉ាង ដើម្បីបំពេញបេសកកម្មតាមបទបញ្ជារាជរដ្ឋាភិបាល ទោះបីជាមិនទាន់មានកញ្ចប់ថវិកាដើម្បីគាំទ្រកិច្ចប្រតិបត្តិការនេះក៏ដោយ ។

ពាក់ព័ន្ធនឹងការងារបច្ចេកទេសនៃកិច្ចប្រតិបត្តិការស្រង់គ្រាប់យុទ្ធភណ្ឌ

៣៩



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/xzzk/ Page 33 of 68



# សម្តេចក្រឡាហោម អញ្ជើញដឹកនាំកិច្ចប្រជុំ
## តាមដានដោះស្រាយសំណើ សំណូមពរ មតិយោបល់



កាលពីរសៀលថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំ ប្រកាសសេចក្តីសម្រេច **បង្កើតក្រុមការងារតាមដានដោះស្រាយសំណើ សំណូមពរ មតិយោបល់របស់មហាជនក្នុងទំព័រហ្វេសប៊ុក** (Facebook Page) សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ ។







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ប្រកាសសេចក្តីសម្រេចបង្កើតក្រុមការងារ
## របស់មហាជន ក្នុងទំព័រហ្វេសប៊ុក របស់សម្តេច







**សម្តេចក្រឡាហោម** បានមាន ប្រសាសន៍គូសបញ្ជាក់ថា៖ ការតាមដានសំណើ សំណូមពរ និងមតិយោបល់មហាជន ឬប្រជាពលរដ្ឋក្នុងបណ្តាញសង្គមនេះ ប្រៀបបាននឹងការឆ្លុះកញ្ចក់មួយរដូច្នេះដែរ ព្រោះថាការទទួលប្រមូលសំណើ សំណូមពរ និងមតិយោបល់តាមបណ្តាញសង្គមនេះ ក៏ជាការឆ្លើយ

៤០



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន
## ក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ (HSI) អមស្ថានទូត




កាលពីព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតឲ្យ លោក **ជេម ផុតប៊យ** (JAMES PODBOY) តំណាងក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ HSI អមស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ









៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# អនុញ្ញាតិឲ្យលោក JAMES PODBOY តំណាង អាមេរិកប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ





នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

នៅក្នុងជំនួបនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានមានប្រសាសន៍ស្វាគមន៍ចំពោះ លោក **ខេម គុតបិយ** តំណាងក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ HSI អមស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការី និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នអនុវត្តច្បាប់នៃប្រទេសទាំងពីរនាពេលកន្លងមក រួមទាំងការផ្លាស់ប្តូរព័ត៌មានបទពិសោធន៍ និងការបណ្តុះបណ្តាល ជាពិសេសការទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងបទល្មើសគ្រឿងញៀន ។

មានមតិឆ្លើយតបវិញ លោក **ខេម គុតបិយ** តំណាងក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ HSI អមស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា បានថ្លែងអំណរគុណដល់នគរបាលកម្ពុជា ដែលបានរួមសហការគ្នាល្អ ក្នុងការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងបទល្មើសគ្រឿងញៀន ។ លោក **ខេម គុតបិយ** ក៏បានថ្លែងនូវការកោតសរសើរដល់ស្ថាប័នអនុវត្តច្បាប់នៃប្រទេសកម្ពុជាដែលបានបំពេញការងារប្រកបដោយវិជ្ជាជីវៈ ជួយឲ្យកម្ពុជារួចផុតពីបញ្ជីឈ្មោះជាប្រទេសគោលដៅទេសចរណ៍ផ្លូវភេទកុមារ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:01 AM

# អគ្គលេខាធិការដ្ឋាន គ ជ ប ជ បើកកិច្ចប្រជុំពិភាក្សា ការរៀបចំកម្មវិធីអន្តរសាសនាលើកទី ៦ សម្រាប់ ឆ្នាំ ២០២២



រសៀលថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២២ កន្លងមកនេះ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ឯកឧត្តម **ស្រី សួន** រដ្ឋលេខាធិការក្រសួងវប្បធម៌ បានអញ្ជើញចូលរួមជាគណៈអធិបតី នៅក្នុងកិច្ចប្រជុំពិភាក្សាការត្រៀមរៀបចំកម្មវិធីអន្តរសាសនាលើកទី៦ ដែលគ្រោងនឹងប្រព្រឹត្តទៅនាពេលខាងមុខនេះ ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងសាសនាធំៗ ទាំងបួន មានតំណាងសាសនាព្រះពុទ្ធ សាសនាគ្រីស្ទកាតូលិក ប្រូតេស្តង់ សាសនាឥស្លាម តំណាងពីអង្គការទីភ្នាក់ងារដៃគូរជាតិ និងអន្តរជាតិ អង្គការការីតាសកម្ពុជា អង្គការ AIM អង្គការចាប់ដៃ អង្គការ







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/xzzk/

Hope of Justice អង្គការយាហ្កា និង មូលនិធិអន្តរជាតិ ។

គូរំលឹកផងដែរថា៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានរៀបចំវេទិកានេះចំនួន ៥ លើករួចមកហើយចាប់តាំងពីឆ្នាំ២០១៧កន្លងមក ។ ដោយឡែកវេទិកានេះត្រូវបានខកខាននៅឆ្នាំ២០២០ និងឆ្នាំ ២០២១ គឺជាពេលវេលាដែលប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូលបានជួបនូវបញ្ហាប្រឈម ដែលបង្កឡើងដោយការរីករាលដាលនៃជំងឺកូវីដ១៩ និងមេរោគបំលែងខ្លួនថ្មីដែល គ.ជ.ប.ជ មិនបានរៀបចំនូវកម្មវិធីជួបជុំទ្រង់ទ្រាយធំឡើយ តែបានរៀបចំជាបទយកការណ៍ និងការផ្សព្វផ្សាយជាទម្រង់វីដេអូ ដែលទទួលបានការអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។**

គូរបញ្ជាក់បន្ថែមទៀតថា៖ គោលបំណងនៃការរៀបចំកិច្ចប្រជុំនេះឡើងគឺដើម្បីស្នើសុំសមាជិកអង្គប្រជុំចូលរួមជាមតិយោបល់ និងដើម្បីផ្តល់ធាតុចូលសំខាន់ៗបន្ថែមទៀតផងដែរ សម្រាប់កម្មវិធីវេទិកាអន្តរសាសនាដែលនឹងប្រារព្ធឡើងនាពេលខាងមុខនេះ ។

វេទិកាអន្តរសាសនាគឺជាមធ្យោបាយមួយដើម្បីជួយធ្វើការផ្សព្វផ្សាយឱ្យបានផ្សែតផ្សៀបដល់ប្រជាពលរដ្ឋនិងកាត់បន្ថយរាល់សកម្មភាពអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកុមារ បង្ហាញនូវភាពសុខដុមរមនានៃសាសនាកម្ពុជា ដែលតែងតែឯកភាពសហការគាំទ្រគ្នាទៅវិញទៅមកដោយភាពទន់ភ្លន់មិនមានទំនាស់ មិនប្រទូស្តសារ៉ាយគ្នា មិនបង្កឲ្យមានការបែកបាក់ និងមហន្តរាយក្នុងសង្គម ។ ផ្ទុយទៅវិញភាពសុខដុមរមនានៃសាសនា បានដើរតួជាគន្លឹះក្នុងការកសាងនូវសន្តិភាពផ្លូវចិត្តរបស់បុគ្គល និងសន្តិសុខក្នុងសង្គមព្រមទាំងជួយពង្រឹងស្មារតីមនុស្សគ្រប់រូបឲ្យរឹងប៉ឹង រួមគ្នាតស៊ូជម្នះនឹងការញុះញង់ អូសទាញដែលជាល្បិចកលខ្សែចង្វាក់ជួញដូរមនុស្ស ។











៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ូ សាគុណ នាំយកអំណោយរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន

## ប្រគល់ជូនសាលាហ្វឹកហ្វឺនជំនាញនគរបាលការពារព្រំដែន



កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ូ សាគុណ** អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែនតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងសហការី បានអញ្ជើញចុះសាកសួរសុខទុក្ខកងកម្លាំង និងនាំយកតុ កៅអី ម៉ាស៊ីន GPS និងកង្ហារធំ ដែលជាអំណោយដ៏ថ្លៃថ្លា របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ទៅប្រគល់ ជូនសាលាហ្វឹកហ្វឺនជំនាញនគរបាលការពារព្រំដែន ខេត្តព្រះវិហារ ។







**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល










អមញ្ជើញមានប្រសាសន៍ក្នុងឱកាសនោះដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ បានបញ្ជាក់ថា៖ អំណោយដ៏ថ្លៃថ្លារបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ដែលត្រូវប្រគល់ ជូនសាលាហ្វឹកហ្វឺនជំនាញនគរបាលការពារព្រំដែន ខេត្តព្រះវិហារ នាពេលនេះ រួមមាន ៖ តុ និងកៅអី ចំនួន៤០០ ម៉ាស៊ីន GPS ចំនួន ៤៥ គ្រឿង និងកង្ហាដ់ចំនួន ៤គ្រឿងដែលកំពុងដំណើរការបើកវគ្គបណ្តុះបណ្តាលជំនាញផែនទី ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងប្រព័ន្ធវាស់វែងទីតាំង ដោយប្រើសញ្ញាផ្កាយរណប (GPS/GNSS) ជំនាន់ទី១ ប្រចាំឆ្នាំ២០២២ ដែលមានកម្មសិក្សាចំនួន ១២៤រូប ។

ក្នុងឱកាសនោះផងដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរង និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន បានរំលឹកដាស់តឿនចំពោះគ្រូបង្វឹក ក៏ដូចជាសិក្ខាកាមទាំងអស់ឱ្យបន្តចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសអនុវត្តឲ្យបានម៉ឺងម៉ាត់នូវអនុសាសន៍ របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី « **៣ការពារ ៣កុំ** » និងវិធានសុខាភិបាល ដើម្បីធានាទាំងសុខុមាលភាពផ្ទាល់ខ្លួនផង និងដើម្បីធានានិរន្តភាពនៃវគ្គបណ្តុះបណ្តាលផង ។

ក្នុងឱកាសនោះដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ ក៏បានបន្តដឹកនាំក្រុមការងារវិស្វកម្មចុះត្រួតពិនិត្យទីតាំងសាងសង់អគារស្នាក់នៅរបស់កងកម្លាំងចំនួន ០៤ខ្នង ស្ថិតនៅក្នុងទីបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគទី៤ ខេត្តព្រះវិហារផងដែរ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ៣០

## សម្តេចក្រឡាហោម អញ្ជើញដឹកនាំកិច្ចប្រជុំ..

ក្រោមទឹកនេះដែរ ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកស៊ីម៉ាក់ (CMAC) បានធ្វើបទបង្ហាញជូន **សម្តេចក្រឡាហោម** និងអង្គប្រជុំអំពីសកម្មភាពនៃកិច្ចប្រតិបត្តិការលទ្ធផល និងបញ្ហាប្រឈមនៃកិច្ចប្រតិបត្តិការ ព្រមទាំងអត្ថប្រយោជន៍ ទាំងលើទិដ្ឋភាពបច្ចេកទេសច្បាប់ និងនយោបាយនៃកិច្ចប្រតិបត្តិការស្រង់គ្រាប់យុទ្ធភណ្ឌក្រោមទឹករបស់រាជរដ្ឋាភិបាល ដែលបាន និងកំពុងអនុវត្តយ៉ាងសកម្មនាពេលនេះ ។

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានធ្វើរបាយការណ៍ជូនអង្គប្រជុំអំពីភារកិច្ចសំខាន់ៗមួយចំនួនរបស់ក្រសួងរ៉ែ និងថាមពល ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការនេះ ដែលក្នុងនោះរួមមានទាំងទិដ្ឋភាពបច្ចេកទេស និងច្បាប់ក្នុងការងារបូមខ្សាច់នៅតំបន់ប្រតិបត្តិការ ដោយនៅក្នុងការដ្ឋានទី៥នេះ ក្រសួងរ៉ែ និងថាមពល បានសម្របសម្រួលដំណើរការបូមខ្សាច់ចេញបានប្រមាណជាង៥រយ៨ពាន់ម៉ែត្រត្រីគុណ ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍គូសបញ្ជាក់ថា៖ រាជរដ្ឋាភិបាលបានដាក់គោលដៅបោសសម្អាតគ្រាប់យុទ្ធភណ្ឌក្រោមទឹកដែលបន្សល់ពីសម័យសង្គ្រាមឱ្យអស់ដើម្បីសុវត្ថិភាពប្រជាពលរដ្ឋ និងសម្រួលដល់ដំណើរនាវាចរណ៍ រួមទាំងការងារផ្សេងទៀតពាក់ព័ន្ធនឹងទន្លេ ដែលក្នុងនោះ**សម្តេច** បានវាយតម្លៃខ្ពស់ចំពោះមន្ត្រីក្រុមការងារជំនាញពាក់ព័ន្ធទាំងអស់ដែលបានខិតខំធ្វើពលិកម្ម បោសសម្អាតគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះក្រោមទឹក និងស្រង់នាវាលិចក្នុងបាតទន្លេបានជាបន្តបន្ទាប់ ទោះបីជាមានឧបសគ្គខ្លះក៏ដោយ ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** បានបន្តលើកទឹកចិត្តឱ្យថ្នាក់ដឹកនាំ និងក្រុមការងារប្រតិបត្តិការបោសសម្អាតគ្រាប់យុទ្ធភណ្ឌក្រោមទឹកបន្តការបំពេញបេសកកម្មឱ្យទទួលបានជោគជ័យ ។ ជាមួយគ្នានេះ **សម្តេច** ក៏បានមានប្រសាសន៍បញ្ជាក់ដែរថា៖ ចំពោះបញ្ហាប្រឈមមួយចំនួនដែលក្រុមការងារបានលើកឡើងក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការនេះ **សម្តេច** រួមទាំងថ្នាក់ដឹកនាំនឹងខិតខំជំរុញការដោះស្រាយ ដើម្បីធានាគាំទ្រដំណើរការប្រតិបត្តិការរបស់ក្រុមការងារឱ្យប្រព្រឹត្តិទៅដោយរលូន ។៚



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







តមកពីទំព័រ ៣២

## សម្តេចក្រឡាហោម អញ្ជើញដឹកនាំកិច្ចប្រជុំ...

តបតាមសេចក្តីប៉ងប្រាថ្នារបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដែល**សម្តេច** បានណែនាំឱ្យក្រសួង-ស្ថាប័នទាំងអស់ តាមដានមតិយោបល់របស់ប្រជាពលរដ្ឋលើបណ្តាញសង្គម ហើយខិតខំដោះស្រាយឱ្យបានទាន់ពេលវេលា ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ទៀតថា៖ បន្ទាប់ពីបង្កើតក្រុមការងារតាមដានសំណើ សំណូមពរ និងមតិយោបល់មហាជនរយៈពេលប្រមាណ២ឆ្នាំមក សង្កេតឃើញថាមានមហាជនកាន់តែច្រើនឡើងបានដាក់សំណើ សំណូមពរ និងលើកមតិយោបល់ជាច្រើនមកកាន់ផេកហ្វេសប៊ុក **សម្តេច** ហេតុដូច្នេះហើយទើប **សម្តេច** សម្រេចកែសម្រួលក្រុមការងារនេះដោយដាក់បញ្ចូលបន្ថែមនូវមន្ត្រីនៃអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រសួងមហាផ្ទៃ ដើម្បីបង្កើនការជឿជាក់ និងមានទំនុកចិត្តពីមហាជន ។

ឯកឧត្តម នាយឧត្តមសេនីយ៍ **ជា សុគន្ធា** អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ បានរាយការណ៍ជូនកិច្ចប្រជុំឱ្យដឹងថា៖ បន្ទាប់ពីត្រូវបានបង្កើតឡើងកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ក្រុមការងារបានបង្ហោះផ្សាយផ្ទាល់សកម្មភាពការងារ **សម្តេចក្រឡាហោម** និងបង្ហោះផ្សាយអត្ថបទ រូបភាព និងវីដេអូ ពាក់ព័ន្ធនឹងកិច្ចការរបស់ **សម្តេចក្រឡាហោម** និងក្រសួងមហាផ្ទៃ និងបានដកស្រង់សំណើ សំណូមពរ និងមតិយោបល់របស់មហាជន គោរពជូន **សម្តេចក្រឡាហោម** ជ្រាប និងពិនិត្យសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ បានចំនួន២.០៥៦ ករណី ។

ឯកឧត្តម អនុរដ្ឋលេខាធិការ បានបន្តថា៖ ក្រុមការងារនឹងបន្តការបង្ហោះផ្សាយផ្ទាល់សកម្មភាពការងាររបស់ **សម្តេចក្រឡាហោម** និងបង្ហោះផ្សាយអត្ថបទ រូបភាព និងវីដេអូ ពាក់ព័ន្ធនឹងកិច្ចការរបស់ **សម្តេចក្រឡាហោម** និងក្រសួងមហាផ្ទៃ ក្នុងទំព័រហ្វេសប៊ុក **សម្តេច** ដកស្រង់សំណើ សំណូមពរ និងមតិយោបល់របស់មហាជន (Comment) ក្នុងទំព័រហ្វេសប៊ុក **សម្តេចក្រឡាហោម** ដើម្បីគោរពជូន **សម្តេច** ជ្រាបនិងពិនិត្យសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ព្រមទាំងបន្តតាមដាន និងជំរុញការដោះស្រាយរាល់សំណើ សំណូមពរ និងមតិយោបល់របស់មហាជន ក្នុងទំព័រហ្វេសប៊ុក **សម្តេចក្រឡាហោម** ។

ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ គត្តិ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ បានអានសេចក្តីសម្រេច ស្តីពី ការបង្កើតក្រុមការងារតាមដានដោះស្រាយសំណើ សំណូមពរ និងមតិយោបល់របស់មហាជន ហៅកាត់ថា **ក្រុមការងារហ្វេសប៊ុកផេកសម្តេចក្រឡាហោម ស ខេង** ដែលក្រុមការងារនេះ មាន ឯកឧត្តម **ជា សុគន្ធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជានាយករងខុទ្ទកាល័យ **សម្តេចក្រឡាហោម** ជាប្រធាន អមដោយអនុប្រធាន និងសមាជិកមួយចំនួនទៀត ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

តមកពីទំព័រ ១៤

## សម្តេចក្រឡាហោម អញ្ជើញពិនិត្យ......

នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងជាសមាជិកក្រុមការងារបច្ចេកទេសសាងសង់ បានឱ្យដឹងថា៖ គិតត្រឹមថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ក្រុមហ៊ុនសាងសង់បានសម្រេចចាក់បេតុងនៅជាន់ទី៧រួចរាល់តាមផែនការកំណត់ ដែលលទ្ធផលនេះ គឺក្រុមហ៊ុនសាងសង់បានដំណើរការលឿនជាងផែនការ១២ ភាគរយ ។ ហើយប្រសិនបើក្រុមហ៊ុនដំណើរការក្នុងសកម្មភាពលឿនដូចកន្លងមកនេះដោយពុំមានឧបសគ្គអ្វីរំខាន ឬរាំងស្ទះដំណើរការទេនោះយើងអាចសន្និដ្ឋានបានថា៖ ដំណើរការសាងសង់ទីស្តីការថ្មីក្រសួងមហាផ្ទៃ និងអាចបញ្ចប់ជាស្ថាពរតាមការគ្រោងទុកឬក៏អាចបញ្ចប់មុនការគ្រោងទុកដែលបានកំណត់ នាចុងខែមិថុនា ឆ្នាំ២០២៣ ៕






# ព្យាបាល និងដាក់ធ្មេញមិនគិតថ្លៃ

**មន្ទីរពេទ្យ ១៦ ឧសភា** របស់នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

សូមជូនដំណឹងដល់កងកម្លាំងនគរបាលជាតិ និងប្រជាជនទូទៅទាំងអស់ឱ្យបានជ្រាបថា : **មន្ទីរពេទ្យ ១៦ ឧសភា** បានរៀបចំព្យាបាលធ្មេញដោយឥតគិតថ្លៃ ។

**ក្នុងនោះមាន :**

- **ដកធ្មេញ**
- **សំអាតធ្មេញ**
- **ប៉ះធ្មេញ**
- **ព្យាបាលធ្មេញ**

**ចំពោះ**មន្ត្រីនគរបាលជាតិគ្រប់អង្គភាពទូទាំងប្រទេសដែលចង់មកទទួលសេវាដាក់ធ្មេញមិនមានគិតថ្លៃអ្វីទាំងអស់ត្រូវមាន ***(អត្តសញ្ញាណប័ណ្ណនគរបាល)*** ។

**⁎ បញ្ជាក់: ដោយឡែកប្រជាជនទូទៅមានតំលៃដូចខាងក្រោម :**

*-តម្លៃធ្មេញធម្មតា ១គ្រាប់ ១០$ (តម្លៃទីផ្សារខាងក្រៅ ១គ្រាប់ ៣០$*

*-តម្លៃធ្មេញ Ceramic ១គ្រាប់ ៣០$ (តម្លៃទីផ្សារខាងក្រៅ១គ្រាប់ ៨០$*

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ : 092 645 171, 015 75 79 79*





# វេជ្ជបណ្ឌិត ញ៉ែម សុខន

**បន្ទប់ពិនិត្យ ពិគ្រោះនិងព្យាបាលជំងឺទូទៅ**

**- ឯកទេសផ្នែកជំងឺទូទៅ និងរូបភាពវេជ្ជសាស្ត្រ**

មានពិនិត្យអេកូសាស្ត្រពណ៌ផ្នែក :

- សរីរាង្គក្នុងពោះមាន: ថ្លើម, ប្រមាត់, លំពែង, បំពង់បង្ហូរទឹកប្រមាត់, តម្រងនោម។
- សរីរាង្គភេទស្ត្រី: ស្បូន, ដៃស្បូន, និងពិនិត្យផ្ទៃពោះ សរីរាង្គក្រពេញទីរ៉ូអ៊ីដ : ពកក

**- មានបទពិសោធន៍ក្នុងការងារពិនិត្យ និងព្យាបាលជំងឺរយៈពេល ២០ឆ្នាំ ។**

**បញ្ចុះតម្លៃ ១០%**
សម្រាប់មន្ត្រីនគរបាលជាតិ





អាសយដ្ឋានផ្ទះលេខ១៣៨អឺសូន្យ ផ្លូវ២១៥ (នេរុហ៍) សង្កាត់វាលវង់ ខណ្ឌ៧ មករា រាជធានីភ្នំពេញ (ខាងត្បូងស្តុបផ្សារដេប៉ូចម្ងាយ៥០ម៉ែត្រ)

ទូរស័ព្ទ: 097 2666 215 / 012 848 917



# មើមខ្ញី អាចបន្សាបជាតិពុលក្នុងរាងកាយ កាត់បន្ថយជាតិខ្លាញ់ និងបំបាត់អាការៈតឹងច្រមុះ

មើមខ្ញីមិនមែនមានអត្ថប្រយោជន៍តែមួយមុខខាងម្ហូបអាហារនោះទេ វាក៏មានថាមពលដ៏អស្ចារ្យផ្សេងទៀតដូចជា ប្រយុទ្ធប្រឆាំងនឹងកោសិកាមហារីក បន្សាបជាតិពុលក្នុងរាងកាយ កាត់បន្ថយជាតិខ្លាញ់នៅក្នុងខ្លួន និងជួយបំបាត់អាការៈតឹងច្រមុះយ៉ាងមានប្រសិទ្ធភាពទៀតផង ។ ប៉ុន្តែមុននឹងយកទៅដាក់ក្រោមខ្នើយ អ្នកត្រូវប្រាកដក្នុងចិត្តថាមើមខ្ញីនឹងស្រស់ល្អ មានអនាម័យត្រឹមត្រូវ ។

១. មើមខ្ញីនឹងជួយបំបាត់បញ្ហាផ្លូវដង្ហើមច្រមុះអ្នកដែលធ្លាប់តែហៀរសំបោរតឹងស៊ីងនឹងចាប់ផ្ដើមធូរស្រាលបន្ទាប់ពីធុំក្លិនមើមខ្ញី ។ នេះក៏ព្រោះតែវាសម្បូរទៅដោយឥទ្ធិពលពិសេសដែលភាយចេញពីមើមខ្ញីទៅប្រយុទ្ធប្រឆាំងនឹងមេរោគ ដើម្បីការពារការឆ្លងមេរោគ ជួយសម្អាតផ្លូវដង្ហើមរបស់អ្នកធ្វើឲ្យច្រមុះនឹងធូរដកដង្ហើមបានស្រួល ។



២.មើមខ្ញីមានសមត្ថភាពបំផ្លាញបាក់តេរីអាក្រក់គ្រប់ប្រភេទ ព្រោះវាមានលក្ខណសម្បត្តិប្រឆាំងដ៏ពិសេសមិនគួរឲ្យជឿ ។ ប្រសិនបើដាក់ខ្ញីនៅក្រោមខ្នើយដែលគេងរាល់យប់រហូតក្លាយជាទម្លាប់ អ្នកនឹងមានអារម្មណ៍ស្រស់ស្រាយរៀងរាល់ព្រឹក ។

៣. សត្វល្អិតទាំងឡាយមិនត្រូវគ្នានឹងមើមខ្ញីទេ បើអ្នកធ្លាប់បារម្ភថានឹងមានមូសខាំ មានខ្ទួយ ក្រុម ឬ សត្វល្អិតស្រមោច ពីងពាងចូលត្រចៀកពេលគេងលក់ វិធីនេះអាចដោះស្រាយបញ្ហាបានយ៉ាងមានប្រសិទ្ធភាព ។

៤. នៅក្នុងមើមខ្ញី វាមានវីតាមីនយ៉ាងពិសេសអស្ចារ្យមួយបែបដែលមានឥទ្ធិពលវិជ្ជមានទៅលើប្រព័ន្ធសរសៃប្រសាទរបស់អ្នកធ្វើឲ្យអ្នកមានអារម្មណ៍ស្ងប់ និងជួយបន្ធូរភាពតានតឹង ហើយក៏គេងលក់យ៉ាងស្កប់ស្កល់ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ១០

## វគ្គសុក្រឹតការថ្នាក់ដឹកនាំ នគរបាលកម្រិត១....

ដ្ឋាននានា អង្គភាព មន្ត្រី និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានខិតខំរៀបចំវគ្គបណ្តុះបណ្តាលនេះឱ្យទទួលបានជោគជ័យ បន្ថែមលើអ្វីដែលបណ្ឌិត្យសភាននគរបាលបានធ្វើជាច្រើន ក្នុងការបណ្តុះបណ្តាលធនធានមនុស្សផ្នែកនគរបាលជាតិ ដើម្បីធានាដល់កិច្ចប្រតិបត្តិការ និងការបំពេញ







បេសកកម្មរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរជូនជាតិ និងប្រជាជន ។

ពាក់ព័ន្ធនឹងភាពចាំបាច់នៃការឆ្លងកាត់ការបណ្តុះបណ្តាលនេះដែរ **សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ថា៖ ការបណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំមន្ត្រីនគរបាលដូចដែលទើបតែបញ្ចប់នេះ ត្រូវតែបន្តដំណើរការទៅមុខទៀត គឺគ្មានជម្រើសអ្វីក្រៅពីការរៀនសូត្រនោះទេ ព្រោះការបណ្តុះបណ្តាលនេះ  មួយវិញទៀតគឺដើម្បីមុខមាត់យើងម្នាក់ៗកុំឱ្យពាក់ផ្កាយតែអត់បានរៀនប៉ូលីសដែលអាចធ្វើឱ្យបាត់តម្លៃ និងកិត្តិយស ។ មិនតែប៉ុណ្ណោះការបណ្តុះបណ្តាលនេះក៏ដើម្បីជាគំរូសម្រាប់កូនចៅជាមន្ត្រីនគរបាលផងដែរ ។ លើសពីនេះទៀតការបណ្តុះបណ្តាលនេះ គឺជាការឆ្លើយតបតាមគោលការណ៍ ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាលធ្វើយ៉ាងណាឱ្យកងកម្លាំងនគរបាលជាតិយើងជាកម្លាំងមានចំណេះ និងជំនាញពិតប្រាកដ មានសីលធម៌ និងគុណធម៌ ។ ដូច្នេះបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលនេះទៅក៏មិនមែនមានន័យថា បានរៀនហើយក៏ចប់ដែរនោះទេ គឺត្រូវរៀនបន្តដោយរៀនលើការងារជាក់ស្តែង ទោះជាធ្លាប់បានធ្វើការងារជាក់ស្តែងហើយក៏ដោយតែក្រោយពីរៀននេះទៀត មន្ត្រីម្នាក់ៗក៏អាចមានគំនិតថ្មីៗលើការបន្តធ្វើការងារជាក់ស្តែងបន្ថែមទៀត ៕



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



តមកពីទំព័រ ១២

## សម្តេចក្រឡាហោម អនុញ្ញាតិឲ្យអនុរដ្ឋមន្ត្រី.....

ជាមួយគ្នានេះ **សម្តេចក្រឡាហោម** ក៏បានសម្តែងការសោកស្តាយចំពោះការទទួលមរណភាព ឯកឧត្តម Shinzo Abe (**ស៊ិន ហ្សូអាបេ**) ដោយ**សម្តេច** បានចាត់ទុកការបាត់បង់ ឯកឧត្តម Shinzo Abe (**ស៊ិន ហ្សូអាបេ**) ថាជាការបាត់បង់មិនត្រឹមតែសម្រាប់ប្រជាជនជប៉ុននោះទេ ប៉ុន្តែក៏ជាការបាត់បង់ឥស្សរជនមួយរូបរបស់ពិភពលោកផងដែរ ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការច្បាប់ និងវិស័យយុត្តិធម៌ **សម្តេចក្រឡាហោម** បានសម្តែងការគាំទ្រចំពោះការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីយុត្តិធម៌ ជប៉ុន-អាស៊ាន និងចាត់ទុកកិច្ចសហប្រតិបត្តិការនេះ គឺជាឱកាសដ៏ល្អក្នុងការចែករំលែកបទពិសោធន៍ជាមួយជប៉ុន ទាំងវិស័យយុត្តិធម៌ វិស័យពន្ធនាគារ និងវិស័យអន្តោប្រវេសន៍ ។

ចំពោះកិច្ចសហប្រតិបត្តិការវិស័យពន្ធនាគារ **សម្តេចក្រឡាហោម** បានមានប្រសាសន៍ បញ្ជាក់ថា៖ ជាការពិតណាស់ការងារពន្ធនាគារនេះស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ហើយក្រសួងក៏មានកិច្ចសហប្រតិបត្តិការជាមួយក្រសួងយុត្តិធម៌ដែរ ។ ទន្ទឹមនេះនៅកម្ពុជា បច្ចុប្បន្នកំពុងមានការប្រឈម នឹងបញ្ហាចង្អៀតណែនក្នុងពន្ធនាគារ ក្នុងនោះរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ បានដាក់ចេញវិធានការផ្សេងៗ រួមមានការបន្ធូរបន្ថយទោសក្នុងឱកាសបុណ្យជាតិផ្សេងៗ ការអនុវត្តទោសក្នុងសហគមន៍ និងការដោះលែងដោយមានលក្ខខណ្ឌ ។

ពាក់ព័ន្ធនឹងការងារក្នុងវិស័យអន្តោប្រវេសន៍វិញ **សម្តេចក្រឡាហោម** បានបញ្ជាក់ថា ពីមុនការងារនេះស្ថិតក្រោមអគ្គស្នងការដ្ឋាននគរបាលជាតិ តែដោយសារការងារនេះរីកកាន់តែធំទៅទើបរាជរដ្ឋាភិបាលសម្រេចបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ព្រោះសព្វថ្ងៃនេះជនអន្តោប្រវេសន្តបរទេសកំពុងមានវត្តមាននៅកម្ពុជាប្រមាណ៩ម៉ឺននាក់ ហើយរាជរដ្ឋាភិបាលកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រងការងារនេះ ។

**សម្តេច** បន្តថារាជរដ្ឋាភិបាលកម្ពុជាកំពុងសហការជាមួយ ADB បង្កើត និងរៀបចំសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីបណ្តុះបណ្តាលមន្ត្រីថ្នាក់ក្រោមជាតិ ក្នុងដំណើរការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ លើកកម្ពស់ស្ថិរភាពជាតិកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ភាពជាម្ចាស់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហានេះ **សម្តេច** ក៏សង្ឃឹមថែរថារដ្ឋាភិបាល និងប្រជាជនជប៉ុន និងបន្តគាំទ្រដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ ហើយ **សម្តេច** ក៏ត្រៀមខ្លួនចាត់បញ្ជូនមន្ត្រីចូលរួមកិច្ចប្រជុំ និងវេទិកាទាំងពីរនៅប្រទេសជប៉ុនដែលគ្រោងរៀបចំនៅចុងឆ្នាំនេះផងដែរ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




SK Teeth Whitening Powder

ជាប្រភេទម្សៅដុះធ្មេញឲ្យស សម្រាប់អ្នកដែលមិនមានពេលទំនេរច្រើន ។ ហើយក៏អាចប្រើជាមួយឈុត Home Kit សម្រាប់ប្រភេទធ្មេញល្បឿងខ្លាំងពីកំណើត ។ លក្ខណៈពិសេសរបស់វាគឺមានតួនាទីជួយសំអាតជាតិកំបោរលើធ្មេញបានយ៉ាងល្អ ។ ប្រើរយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។




SK Luxury Kit

ជាប្រភេទពន្លឺធ្វើអោយធ្មេញស ដែលមានមុខងារពិសេស។ ជាច្រើនរួមបញ្ចូលគ្នាក្នុងប្រអប់ Luxury Kit តែមួយ ។ មានវីតាមីនជួយការពារធ្មេញ អញ្ចាញធ្មេញ និងការពារស្រៀវស្រគា។ Luxury Kit Design ឡើងយ៉ាងសាកសមបំផុតសម្រាប់មនុស្សសម័យថ្មី ផ្លែផ្គរជាមួយនិងបច្ចេកវិទ្យាទំនើប និងការវិចខ្ចប់ដ៏ស្រស់ស្អាត។ អាចធ្វើជាការជូនជូនមនុស្សជាទីស្រលាញ់ ។ ប្រើប្រាស់រយៈពេល៧ថ្ងៃឃើញលទ្ធផល។




Set Luxury + Powder

ឈុតពិសេសសំរាប់ធ្មេញល្បឿងខ្លាំងពីកំណើត

| | |
|---|---|
| -ប្រើបាន ២៨ ដង | -គុណភាពសល្បឿន គុណានិង២ |
| -មានអនាម័យខ្ពស់ ការវិចខ្ចប់ខ្ពស់ | -មានវិតាមីន C ការពារអញ្ចាញ |
| -មាន Florine ការពារធ្មេញពុក | -មាន Potassium nitrate ការពារស្រៀវ រី ស្រគាធ្មេញ |

-ជួយធ្វើអោយធ្មេញភ្លឺរលោង សស្អាត កំចាត់កំនរកំបោរ និងស្នឹបខ្មៅៗ លើធ្មេញប្រើរយៈពេល ៥ថ្ងៃ ចាប់ផ្តើមឃើញធ្វើប្លែក ។




SK Home Kit Teeth Whitening

សម្រាប់ប្រភេទធ្មេញធម្មតាជាប្រភេទពន្លឺធ្វើអោយធ្មេញស ប្រើដោយខ្លួនឯងនៅផ្ទះ ដោយមិនចាំបាច់ចំណាយពេលវេលា Clinic សម្រាប់ប្រភេទធ្មេញល្បឿងធម្មតា មិនស្រៀវ មិនល្បឿងពីកំណើត ប្រើប្រាស់រយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។










Madamk Menbrane Gel

ជួយផ្តល់សំណើមយ៉ាងល្អដល់ស្បែកមុខ

បំបាត់នូវបញ្ហា

-រមាស់ -ក្របាម -របកស្បែក -រលាល

Madamk Healing Set Membrane Gel Add Oil

ជាប្រភេទឡេលាបថែរក្សា និង បំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចរ៉ុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់រាល់បញ្ហារមាស់ក្របាមខ្លាំង របកស្បែករលាល ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និង ក្រាស់ឡើញវិញ ។

Madamk Healing Set

ជាប្រភេទឡេលាបថែរក្សា និងបំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺមផ្លូរលោង ការពារមុខជាំ អាចម៌រុយ និងជ្រួញ ហើយថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្របាមផងដែរ ។ លក្ខណៈពិសេសគឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នក ដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ ។

ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា  ទូរស័ព្ទ : 017 777 839 / 016 777 839




Madamk Aromatic Nourishing Face Oil

មានមុខងារ

-ជួយបំបាត់មុខក្រហម

-ជួយបំបាត់មុខស្ងើងសរសៃក្រហម

-ជួយស្បែកមានជាតិទឹក ភ្លឺរលោងក្មេងជាងវ័យ ចំពោះអ្នកមានអាយុលើសពី ៣០ឆ្នាំ ឡើងទៅប្រើ Oil នេះរាល់ថ្ងៃវាជួយផ្តល់ជាតិទឹក អោយមុខក្មេងជាងវ័យ និងពន្យាភាពចាស់ផងដែរ។

Madamk Hair Shampoo & Hair Conditioner

មុខងារ :

-ជួយបណ្តុះសក់

-ជួយព្យាបាលសរសៃសក់ដែលខូចខ្លាំង

-ជួយធ្វើអោយសក់ទន់រលោងក្រអូបនិងជួយអោយសក់រឹងមាំ

-លាងជំរះស្បែកក្បាលបានល្អ បំបាត់អង្គែ និងរមាស់







Madamk Advance Eye Essence

-ជាសេរ៉ូលាបភ្នែក វាមានតួនាទី២យ៉ាង ទី១ ព្យាបាល ទី២ បញ្ឈោតភ្លាមៗ

-ជួយអោយភ្នែកបាត់ខ្មៅ បាត់ស្លក់ បាត់ជ្រួញ

-លាបភ្លាមឃើញភ្នែកអន់ខ្មៅ អន់ជ្រួញ អន់ស្លក់ភ្លាមៗ ២០-៣០% (លាងទឹកត្រលប់មកធម្មតាវិញ)

-លាបរយៈពេល ៣ខែឡើង ចាប់ផ្តើមឃើញលទ្ធផល

-លាបចូលអស់មិនកក លាបច្រើនយ៉ាងណាក៏មិនកក និងអាចលាបនៅកន្លែងណាដែលមានស្នាមជ្រួញបានផលដែរ។




Madamk Qwhite Body Lotion

ជាឡេលាបខ្លួនអោយស្បែក ស មង្ករលោង វាមានតួនាទី ៣យ៉ាង :

ទី១ បញ្ឈោតអោយ ស ភ្លាម

ទី២ ធ្វើអោយស្បែក ស ពីខាងក្នុងពិតប្រាកដ

ទី៣ ជួយការពារកំដៅថ្ងៃបានយ៉ាងល្អ។ (លាងទឹកត្រលប់មកធម្មតាវិញ)

-លាបចាប់ពី ៣ខែ ឡើងទើបឃើញលទ្ធផល ស្បែកសភ្លឺចេញពីក្នុង

-ស បែបស្បែកមានសុខភាពល្អ

-ជួយការពារកម្តៅថ្ងៃបានយ៉ាងល្អ SPF 25 រយៈពេល ៣ខែឡើងចាប់ផ្តើមឃើញលទ្ធផល




Madamk Herbal Cream ជា Cream

ផ្សំពីផ្កា ឬសឈើ និងម្សៅគុជខ្យងជួយ :

-បឺតជាតិពុល ជាតិថ្នាំគីមីពីក្រោមស្បែកមុខដែលបន្សល់ពីផលិតផលចាស់

-បំបាត់អាល វីមុខ

-ជួយផ្ចិតរុនញើស

-ជួយអោយមុខភ្លឺរលោង






Madamk Healing Specail

ជាប្រភេទឡេលាបថែរក្សា និងបំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចម័រុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់អាល វី មុនកប់ ជួយផ្ចិតរុញញើស ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្ងើងសរសៃក្រហមបានផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ។

Madamk Armpit Scrub ជាសាប៊ូដុះពេលងូតទឹក

-ជួយបំបាត់ក្លិនក្លៀកភ្លាមៗក្រោយពេលងូតទឹករួច

-ជួយអោយក្លៀក ស មង្គ បាត់ដុំពក មិនមានជាតិថ្នាំពេទ្យដែលប៉ះពាល់ស្បែកក្លៀកទេ។

**ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឬស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839**





ដាក់ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពក្នុងនោះរាប់ទាំងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ជាពិសេសត្រូវយកចិត្តទុកដាក់ដោះស្រាយសំណើរ សំណូមពរ បញ្ហាប្រឈម និងមតិយោបល់ប្រជាពលរដ្ឋឱ្យបានល្អ និងមានប្រសិទ្ធភាព ព្រមទាំងយកចិត្តទុកដាក់ទប់ស្កាប់ការកាប់បំផ្លាញព្រៃឈើ និងថែរក្សាធនធានធម្មជាតិ ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍ថា៖ ទន្ទឹមនឹង ឯកឧត្តម **គីម រិទ្ធី** ចូលកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលខេត្ត និងមានអភិបាលរងខេត្តថ្មី ចូលកាន់តំណែងដែរនោះ ឯកឧត្តម **ប្រាក់ សុវណ្ណ** អតីតអភិបាលខេត្តព្រះវិហារ នឹងត្រូវបន្តទៅឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សា ខេត្តព្រះវិហារ ជំនួស ឯកឧត្តម **ឡុង សុវណ្ណា** ដែលបានសុំលាឈប់ពីប្រធានក្រុមប្រឹក្សាខេត្ត



តមកពីទំព័រ ០៨

**សម្តេចក្រឡាហោម អញ្ជើញជាអធិបតី...**

ស្រុក-ក្រុង-ឃុំ-សង្កាត់ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋផ្តល់ការគាំទ្រចំពោះ ឯកឧត្តម **គីម រិទ្ធី** ក្នុងនាមអភិបាលខេត្តនៃគណៈអភិបាលខេត្តព្រះវិហារ ។

**សម្តេច** ក៏បានផ្តល់ការណែនាំឱ្យរដ្ឋបាលខេត្ត-ក្រុង-ស្រុក និងឃុំ-សង្កាត់ទាំងអស់នៃ ខេត្តព្រះវិហារ យកចិត្តទុក

និងដែលត្រូវបានរាជរដ្ឋាភិបាលតែងតាំងជាទីប្រឹក្សារាជរដ្ឋាភិបាលមានឋានៈស្មើរដ្ឋលេខាធិការ ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







តមកពីទំព័រ ០៦

**សម្តេចក្រឡាហោម អនុញ្ញាតិឲ្យក្រុមនិស្សិត..**

ទាំងអស់អាចនឹងជួបបញ្ហាប្រឈមថ្មីៗ ឬការលំបាកខ្លះៗពុំខានឡើយ ដូច្នេះការតាំងចិត្តតស៊ូ ដោយយកក្តីអត់ធ្មត់ ព្យាយាម និងប្រឹងប្រែងសិក្សាឱ្យអស់ពីលទ្ធភាពពិតជានឹងធ្វើឱ្យជីវិតសិក្សារបស់និស្សិតទាំងអស់កាន់តែមានតម្លៃ ហើយលទ្ធផល ជាវិជ្ជមាននឹងកើតឡើង នាពេលខាងមុខជាក់ជាពុំខានឡើយ ។

បន្ទាប់មកតំណាងក្រុមនិស្សិតជ័យលាភីអាហារូបករណ៍ ដែលមានសមាសភាពជាមន្ត្រីរាជការនៃក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសម្តែងក្តីរីករាយ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូន**សម្តេចក្រឡាហោម** ដែលបានផ្តល់ឱកាសឱ្យក្រុមនិស្សិត បានចូលជួបនាឱកាសនេះ និងសង្ឃឹមថាក្រុមនិស្សិតទាំងអស់នឹងទទួលបានអនុសាសន៍ល្អៗពី **សម្តេចក្រឡាហោម** ។

សូមបញ្ជាក់ថា៖ ក្រុមនិស្សិតដែលបានចូលជួប **សម្តេចក្រឡាហោម** នាឱកាសនេះ គឺជាក្រុមនិស្សិតទទួលបានជ័យលាភីក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន សម្រាប់ការអភិវឌ្ឍធនធានមនុស្ស ហៅកាត់ថា JDS ដែលផ្តោតសំខាន់លើមន្ត្រីរាជការវ័យក្មេងដែលមានសមត្ថភាព និងស្មារតីក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសកម្ពុជា ឱ្យមានការរីកចម្រើនកាន់តែប្រសើរឡើងនានាពេលអនាគត ។


SINCE 1997
WWW.SOKHAGROUP.COM
E: SOKHASUN@SOKHAGROUP.COM
Cell: 012 / 070 8 7777 6
SOKHA
PRINTING HOUSE
#970, STREET BETONG, PHUM ROUNG CHAK,
SANGKAT PHNOM PENH THMEY, KHAN SEN SOK
WE KNOW,
WHAT YOU WANT
MAGAZINE • CATALOGUE • MENU • BOOKLET • ANNUAL REPORT • DIARY • NOTEBOOK • BROCHURE • FLYER • CORPORATE IDENTITY • FOLDER •
CALENDAR • PAPER BAG • PLASTIC BAG • ECO BAG • KEY CHAIN • HAND FAN • PARASOL/UMBRELLA • PEN • T-SHIRT • CAP • BAG • CAKE BOX
• MEDICAL BOX • POSTER • BANNER • BILLBOARD • PRE-PAID CARD • ID CARD • CHEQUE • SECURITY CARD








តមកពីទំព័រ ០២

**គ ជ ប បូកសរុបការងារ បោះឆ្នោត........**

សរសើរការបោះឆ្នោត ខណៈអង្គការសង្កេតការណ៍អន្តរជាតិភាគច្រើនក៏បានចេញសេចក្តីថ្លែងការណ៍វាយតម្លៃខ្ពស់ចំពោះដំណើរការបោះឆ្នោតនេះ និងបានលើកឡើងជាឯកឱ្យថា ការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយរលូនដោយសេរី យុត្តិធម៌ ស្មើភាព សន្តិភាព តម្លាភាព និងស្តង់ដារអន្តរជាតិ តាមគន្លងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស គួរឱ្យកត់សម្គាល់ ។

អញ្ជើញមានប្រសាសន៍នាឱកាសនោះសម្តេចក្រឡាហោម៖ បានសម្តែងនូវការកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគណៈកម្មការជាតិរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អាជ្ញាធរកងកម្លាំងមានសមត្ថកិច្ចគណបក្សនយោបាយនានា អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកពាក់ព័ន្ធនានា ព្រមទាំងប្រជាពលរដ្ឋដែលបានចូលរួមធ្វើឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥នេះទទួលបាននូវលទ្ធផលដ៏ល្អប្រសើរ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់ទៀតថា៖ គ្រប់ដំណាក់កាលនៃការបោះឆ្នោត កម្ពុជាតែងតែបានយកចិត្តទុកដាក់កែលម្អដំណើរការបោះឆ្នោតទាំងក្របខណ្ឌច្បាប់ និងបច្ចេកទេសដោយឈរលើមូលដ្ឋាននៃអនុសាសន៍ និងធាតុចូលពីគ្រប់មជ្ឈដ្ឋាន ព្រមទាំងការតាំងចិត្តចូលរួមដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយភាពស្មោះត្រង់ពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះ **គ.ជ.ប** ក៏បានកែសម្រួលរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានរបស់ខ្លួន ដើម្បីធ្វើឲ្យអង្គភាពនេះ បំពេញភារកិច្ចកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបានធ្វើទំនើបកម្មដំណើរការរៀបចំការបោះឆ្នោតបន្ថែមទៀត ដោយយកចិត្តទុកដាក់លើការបង្កើតកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជន ព្រមទាំងការងារមួយចំនួនទៀតពាក់ព័ន្ធនឹងបច្ចេកវិទ្យា ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ទៀតថា៖ រាជរដ្ឋាភិបាលកម្ពុជាមានការទទួលខុសត្រូវខ្ពស់ក្នុងការលើកកម្ពស់ដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស និងការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ នៅកម្ពុជាដោយធានារក្សាពង្រឹងសន្តិភាព ស្ថិរភាពនយោបាយនិងការអភិវឌ្ឍសង្គមលើគ្រប់វិស័យ ការធានាឯករាជភាព និងស្វ័យភាពរបស់ស្ថាប័នរៀបចំការបោះឆ្នោត និងការកំណត់កាលបរិច្ឆេទបោះឆ្នោត ។ ទន្ទឹមនេះរាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ផ្តល់កិច្ចសហការជាមួយ **គ.ជ.ប** ដើម្បីរក្សាសន្តិសុខបោះឆ្នោតរួមទាំងសន្តិសុខសុវត្ថិភាពដល់គណបក្សនយោបាយ និងបេក្ខជននានា ដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតសកម្មភាព យុទ្ធនាការឃោសនាបោះឆ្នោត សុវត្ថិភាពកន្លែងបោះឆ្នោត កន្លែងរាប់សន្លឹកឆ្នោត សម្ភារបរិក្ខារ បម្រើឲ្យការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត ការធានាដល់ធនធានថវិកាសម្រាប់ **គ.ជ.ប** ចាត់ចែងកិច្ចការនានាក្នុងដំណើរការបោះឆ្នោតប្រកបដោយស្តង់ដារ គុណភាព និងដំណើរការបោះឆ្នោតក្នុងស្ថានភាពកូវីដ-១៩ ។

គួរបញ្ជាក់ដែរថា៖ ក្នុងសន្និបាតរយៈពេល៧ថ្ងៃនេះ **គ.ជ.ប** មានគោលបំណងត្រួតពិនិត្យការងារផ្លាស់ប្តូរយោបល់ ចែករំលែកបទពិសោធល្អៗ វាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយ ការខ្វះខាត ដើម្បីបង្កើនការយល់ដឹងពង្រឹងកិច្ចសហការ និងការអនុវត្តសំដៅកែលម្អការរៀបចំការបោះឆ្នោតខាងមុខឱ្យកាន់តែល្អប្រសើរថែមទៀត ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# អគ្គស្នងការរដ្ឋនគរបាលជាតិ ជំរុញឲ្យមន្ត្រីនគរបាលប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវយល់ដឹងបន្ថែមទៀតពាក់ព័ន្ធនិងការងារប្រឆាំងការសម្អាតសាច់ប្រាក់





ក្នុងកិច្ចប្រជុំស្តីពីការស្រាវជ្រាវបង្ក្រាបបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការងារពាក់ព័ន្ធបទល្មើសសម្អាតប្រាក់ កាលពីព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២កន្លងមកនេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ លោកជំទាវ នាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ បានជំរុញឲ្យមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកអនុវត្តច្បាប់ត្រូវយល់ដឹងបន្ថែមទៀតពាក់ព័ន្ធ និងការងារប្រឆាំងការសម្អាតប្រាក់ ព្រោះការងារសម្អាតប្រាក់ គឺជារឿងសកលទាមទារឲ្យមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់ផងដែរ ។

***លោកជំទាវ នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ*** បានបញ្ជាក់ថា៖ ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកអនុវត្តច្បាប់ពាក់ព័ន្ធនិងការងារប្រឆាំងការជួញដូរមនុស្ស និងការងារអនីតិជន ក៏ត្រូវយល់ដឹងជំនាញបន្ថែមមួយទៀតដែលខានមិនបាននោះ គឺការងារ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





សន្ទុះអាជ្ញាធរបង្ក្រាបបាន ១០១/៤៩ ករណី ឃាត់ខ្លួនជនសង្ស័យ ១០៥/៥១ នាក់ និងសង្គ្រោះជនរងគ្រោះបាន ១០៧/៥០ នាក់ ក្នុងនោះ ( អាយុក្រោម១៥ឆ្នាំ ៦៥នាក់ អាយុ១៥ ដល់១៧ឆ្នាំ ចំនួន ១៤នាក់ អាយុ ១៨ឆ្នាំឡើង ចំនួន ២៣នាក់) ។

ទន្ទឹមនេះការងារបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ អាជ្ញាធរធ្វើការបង្ក្រាបរួម ៩៤/១៥២ករណី





ពាក់ព័ន្ធ និងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលក្នុងនោះមានហិរញ្ញប្បទានដែលបានមកពីបទល្មើសផ្សេងៗទៀត ។ ជាក់ស្តែងរយៈពេលកន្លងមកនេះ ក៏មានករណីជាច្រើនពាក់ព័ន្ធការសម្អាតប្រាក់ដែលក្រុមការងារបង្ក្រាបការសម្អាតប្រាក់ កំពុងធ្វើការស្វែងរកឲ្យឃើញនូវករណីដែលបានបង្កប់នៅក្នុងបទល្មើសដែលបានផលពីបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឲ្យទៅជាការសម្អាតប្រាក់ ។

**គួរបញ្ជាក់ផងដែរថា៖** តាមរបាយការណ៍ប្រចាំឆមាសទី១ ក្នុងឆ្នាំ២០២២ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឲ្យដឹងថា ៖ សម្រាប់ការងារបង្ក្រាបបទល្មើសរំលោភសេព ថយចុះ ៥៨ករណី ស្មើ៣៨.១៥% ចាប់ខ្លួនជនសង្ស័យ ១២៤/២២៣នាក់ ( ស្រី ១៤នាក់) ក្នុងនោះជនបរទេស ១៤នាក់ និងសង្គ្រោះជនរងគ្រោះបាន ៣៩៣/៥១០ នាក់( អាយុក្រោម១៥ឆ្នាំ ១០០នាក់ អាយុ ១៥-១៧ឆ្នាំ ៤៧នាក់ អាយុ១៨ឆ្នាំឡើង ២៤៦នាក់) បញ្ជូនទៅសង្គមកិច្ច ៥នាក់ និងទៅគ្រួសារ ៣៨៨នាក់ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:01 AM

# អគ្គស្នងការដ្ឋាននគរបាលជាតិ ដាក់ចេញការណែនាំ សន្តិសុខឯកជន ដើម្បីពង្រឹងសមត្ថភាពភ្នាក់ងារ




ក្នុងកិច្ចប្រជុំដកបទពិសោធន៍ការងារគ្រប់គ្រងសន្តិសុខឯកជន រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ ជាមួយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងសមាគមគ្រឹះស្ថានជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន(លើកទី២) កាលពីព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ កន្លងមកនេះ ឧត្តមសេនីយ៍ឯក **អ៊ី សុខឃី** អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានផ្តល់នូវការណែនាំមួយចំនួនដល់នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនទាំងអស់ ដើម្បីពង្រឹងសមត្ថភាពភ្នាក់ងាររបស់ខ្លួន សំដៅចូលរួមថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម ជាមួយកងកម្លាំងមានសមត្ថកិច្ចដែលមានជាអាទិ៍៖



ឧត្តមសេនីយ៍ឯក លឹម សុខារស្មី ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន



**ទី១៖** បន្តជំរុញអនុវត្តឲ្យបានត្រឹមត្រូវតាមបទដ្ឋានច្បាប់ អនុក្រឹត្យ ប្រកាសរបស់ក្រសួងមហាផ្ទៃ និងសេចក្តីណែនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅក្នុងការអនុវត្ត ក៏ដូចជាការបំពេញការងារពាក់ព័ន្ធវិស័យសន្តិសុខឯកជន ។ ក្នុងនោះមានការកំណត់អំពីបែបបទនៃការជ្រើសរើសភ្នាក់ងារ,ការប្រើប្រាស់ឯកសណ្ឋាន,សម្ភារបំពាក់ឲ្យភ្នាក់ងារជាដើម។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/xzzk/

# មួយចំនួនដល់ នាយកដ្ឋានជំនាញ និងក្រុមហ៊ុនផ្តល់សេវា របស់ខ្លួនសំដៅចូលរួមថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម

**ទី២៖** សូមឲ្យយកចិត្តទុកដាក់ពិនិត្យឲ្យបានម៉ត់ចត់ក្នុងការជ្រើសរើសភ្នាក់ងារសន្តិសុខ ឲ្យស្របទៅតាមលក្ខខណ្ឌ ។ ចំណុចនេះត្រូវធ្វើកិច្ចការងារដោយប្រុងប្រយ័ត្នជៀសវាងឲ្យបាននូវការជ្រៀតចូលនៃសមាសភាពដែលមិនល្អ ដែលមានគំនិតប៉ុនប៉ងប្រព្រឹត្តបទល្មើសផ្សេងៗ ក្រោមរូបភាពនៃការជ្រើសរើស ហើយបង្កប់ការធ្វើសកម្មភាពក្នុងក្រុមហ៊ុន ឬគ្រឹះស្ថាន ។ សូមលើកទឹកចិត្តឲ្យក្រុមហ៊ុន ឬគ្រឹះស្ថាន ផ្តល់អាទិភាពក្នុងការជ្រើសរើសយកអតីតមន្ត្រី ឬកងកម្លាំងប្រដាប់



ឧត្តមសេនីយ៍ឯក អ៊ី សុខឃី អគ្គស្នងការរងនគរបាលជាតិ





អាវុធដែលបានចូលនិវត្តន៍ពីការងាររដ្ឋ ដែលមានសុខភាពល្អអាចបំពេញការងារឲ្យក្រុមហ៊ុនព្រោះពួកគាត់អាចយល់ដឹងច្រើនអំពីវិធីការពារនិងការងារមួយចំនួនដែលអាចជួយបានដល់ក្រុមហ៊ុន ឬគ្រឹះស្ថាន ។

**ទី៣៖** បន្តសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ឲ្យបានកាន់តែស៊ីជម្រៅ និងបន្តសហការជាមួយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ឲ្យបានល្អក្នុងការធ្វើកិច្ចការរបស់ខ្លួនទាក់ទងនឹងការគ្រប់គ្រងដំណើរការសកម្មភាពការងាររបស់ក្រុមហ៊ុន ក៏ដូចជាគ្រឹះស្ថាន ។ ចំណុចនេះទាមទារឲ្យមានការអនុវត្តច្រើន ព្រោះកិច្ចសហការនេះជាការធានានូវនិរន្តរភាពនៃដំណើរការរបស់គ្រឹះស្ថាន ឬក្រុមហ៊ុន ។

**ទី៤៖** សមត្ថកិច្ចត្រូវយកចិត្តទុកដាក់បណ្តាគ្រឹះស្ថានដែលនៅក្នុងភូមិសាស្ត្ររបស់ខ្លួន ពិសេសបណ្តាខេត្ត ដែលមានភូមិសាស្ត្រស្មុគស្មាញ ត្រូវគ្រប់គ្រងឲ្យបានបណ្តាទីតាំងដែលប្រើប្រាស់ភ្នាក់ងារសន្តិសុខឯកជន ។ សម្រាប់ក្រុមហ៊ុន ឬគ្រឹះស្ថានត្រូវយកចិត្តទុកដាក់គ្រប់គ្រងភ្នាក់ងាររបស់ខ្លួនឲ្យណែននៅក្នុងវេន ព្រោះការគ្រប់គ្រងនេះសំខាន់ណាស់ ដោយហេតុថា ខ្លាចភ្នាក់ងាររបស់ខ្លួនដាក់ទៅប្រើប្រាស់ទំនាក់ទំនងនៅខាងក្រៅ ហើយធ្វើសកម្មភាពនៅគោលដៅណែរដើងដោយខុសច្បាប់ ។

**ទី៥៖** លើកកម្ពស់ និងគាំទ្រការបណ្តុះបណ្តាលជំនាញភ្នាក់ងារសន្តិសុខឯកជន ដោយស្នើឲ្យនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន បន្តបើកវគ្គបណ្តុះបណ្តាលនេះបន្ថែមទៀត ដើម្បីពង្រឹងសមត្ថភាពលើកស្ទួយជំនាញ ៕

# នគរបាលបច្ចេកទេសព្រំដែន ចុះត្រួតពិនិត្យទីតាំងសាងសង់ លេណដ្ឋានចំនួន ៣៩ ក្នុងទិសភូមិភាគទី ៣ , ៤ និងទី ៥




អនុវត្តតាមគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ កាលពីថ្ងៃទី១០ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ឧត្តមសេនីយ៍ឯក **ខូ ហាក់** ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន បានដឹកនាំកម្លាំងជំនាញចុះត្រួតពិនិត្យទីតាំងសាងសង់លេណដ្ឋានចំនួន **៣៩លេណដ្ឋាន** ក្នុងទិសភូមិភាគទី៣-៤ និងទី៥ និងពិនិត្យទីតាំងសាងសង់អគារប៉ុស្តិ៍ចំនួន ១ប៉ុស្តិ៍ និងផ្ទះបាយ ១ខ្នង ក្នុងទិសភូមិភាគ៥ ។

ឧត្តមសេនីយ៍ឯក ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន បានបញ្ជាក់ឱ្យដឹងថា៖ ទីតាំងសាងសង់លេណដ្ឋាន ចំនួន**៣៩**កន្លែងនេះ គឺភូមិភាគទី៥ ៖

**-ខេត្តបន្ទាយមានជ័យ** ៖ វរសេនាតូចលេខ៨៩១ ចំនួន២លេណដ្ឋាន វរសេនាតូចលេខ៨០៧ មានចំនួន ២លេណដ្ឋាន និងវរសេនាតូចលេខ៨១១ មានចំនួន ៤លេណដ្ឋាន វរសេនាតូចលេខ៨១៥ ចំនួន ២លេណដ្ឋាន ។





**-ខេត្តបាត់ដំបង** ៖ វរសេនាតូចលេខ ៨១៧ មានចំនួន ២លេណដ្ឋាន វរសេនា



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









តូចលេខ៨១៩ មានចំនួន ២លេណដ្ឋាន វរសេនាតូចលេខ៣១០ មានចំនួន ២ លេណដ្ឋាន ។

**-ខេត្តពោធិ៍សាត់៖** វរសេនាតូចលេខ៨៧៥ មានចំនួន ១លេណដ្ឋាន ។

**-ខេត្តប៉ៃលិន៖** វរសេនាតូចលេខ៨៧១ មានចំនួន ២លេណដ្ឋាន ។

**-ខេត្តព្រះវិហារ** ( ភូមិភាគទី៤ )៖ វរសេនាតូចលេខ១០៥ មានចំនួន ២លេណដ្ឋាន វរសេនាតូចលេខ៧៩៣ មានចំនួន ៤លេណដ្ឋាន វរសេនាតូចលេខ៧៩៥ មានចំនួន ៥លេណដ្ឋាន ។

**-ខេត្តឧត្ដរមានជ័យ៖** វរសេនាតូចលេខ៧០២ មានចំនួន ៣លេណដ្ឋាន វរសេនាតូចលេខ៩០៥ មានចំនួន ៤លេណដ្ឋាន ។

**-ខេត្តកោះកុង** ( ភូមិភាគទី ៣ ) ៖ វរសេនាតូចលេខ៨៣៧ ចំនួន ២លេណដ្ឋាននឹងបានបន្តចុះទៅត្រួតពិនិត្យទីតាំងសាងសង់អគារប៉ុស្តិ៍ចំនួន ១ប៉ុស្តិ៍ និង ផ្ទះបាយ ១ខ្នង នៃប៉ុស្តិ៍រំអូរល្ហុងចំណុះវរសេនាតូចលេខ៨៩១ ស្ថិតនៅភូមិសន្តិភាព ឃុំទួលពង្រ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលតាមការវាយតម្លៃរបស់ក្រុមការងារ គឺគ្រប់ចំណុចទាំង៣៩សុទ្ធតែអាចសាងសង់បានទាំងអស់ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# អ្វីទៅជាជំងឺអុតស្វា (MonkeyPox) ?









ជំងឺនេះ ត្រូវបានអង្គការសុខភាពពិភពលោកបានប្រកាសថា ជាភាពអាសន្នសុខភាពសាធារណៈហើយក៏ជាក្តីកង្វល់អន្តរជាតិ(PHEIC)ដែលទាមទារសូមឱ្យមានការលើកកម្ពស់សម្របសម្រួលនៃការឆ្លើយតបជាលក្ខណៈអន្តរជាតិទើបអាចទប់ស្កាត់ពីការរីករាលដាលនេះបាន។

តាមគេហទំព័ររបស់អង្គការសុខភាពពិភពលោកដែលបានលើកឡើងបន្ថែមទៀតថា ជំងឺអុតស្វា គឺមានត្រឡាយវីរុសអំបូរដូចគ្នានៃជំងឺអុតស្វាយខណៈដែលរោគសញ្ញាមានលក្ខណៈស្រដៀងគ្នានៃរោគសញ្ញាជម្ងឺអុតស្វាយដែរ ។

ដោយឡែកវ៉ាក់សាំង និងឱសថត្រូវបានគេយកវ៉ាក់សាំងរបស់អុតស្វាយមកប្រើប្រាស់ដែរ មានប្រសិទ្ធភាពអាចប្រើប្រាស់ទប់ស្កាត់ជំងឺអុតស្វាបាន ។

គេរកឃើញជំងឺអុតស្វាបានឆ្លងរហូតដល់ទៅជាង១ម៉ឺន៦ពាន់ករណីហើយដែលត្រូវបានគេរាយការណ៍ចេញពីប្រទេសចំនួន៧៥ នៅពាសពេញពិភពលោក ហើយតួលេខខាងលើនេះ ត្រូវបានគេអះអាងបន្ថែមទៀតថា វាបានឆ្លងកើនឡើងកំរិតខ្ពស់រហូតដល់ទៅ៧៧%ឯណោះ ដោយរាប់តាំងពីចុងខែមិថុនា រហូតដល់ដើមខែកក្កដានេះ បើតាមអង្គការសុខភាពពិភពលោក និងអង្គការសហប្រជាជាតិបានលើកឡើង ។

ប្រធានរបស់ក្រុមអ្នកឯកទេសលើផែទាំសុខភាពរបស់វេទិកាសេដ្ឋកិច្ចសកល លោក **ស៊ីយ៉ាម ប៊ីសេន** (Shyam Bishen) បានលើកឡើងពាក់ពន្ធ័នឹងរឿងជុំវិញនៃវីរុសនេះ បានគូសបញ្ជាក់ដែរថា តាមរយៈសេចក្តីប្រកាសរបស់អង្គការសុខភាពនៃការផ្ទុះឡើងនូវជំងឺអុតស្វា ត្រូវតែប្រទេសនៅជុំវិញពិភពលោក ដើម្បីរួមចំណែកដោះស្រាយបញ្ហាដែលកំពុងតែប្រឈម និងទប់ស្កាត់កុំឱ្យមានការរាតត្បាតបន្ថែមទៀត ។



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល










ប្រសិនបើយើងក្រឡេកមើលទៅកាន់តំបន់អឺរ៉ុបកាលពីពេលថ្មីៗនេះ ត្រូវបានបណ្តាញផ្សព្វផ្សាយអន្តរជាតិធំៗបានរំលេចឡើងថា តំបន់អឺរ៉ុប បានក្លាយទៅជាទីតាំងដើមចមនៃការរាតត្បាតនូវជំងឺអុតស្វា ខណៈដែលនៅទូទាំងពិភពលោក ត្រូវគេរកឃើញថា មានករណីឆ្លងរហូតដល់ទៅ៨០ករណី ស្របពេលមានអ្នកស្លាប់ប្រមាណជា៤នាក់ ប៉ុន្តែវាជាតួលេខមានចំនួនតិចតួច បើប្រៀបធៀបជាមួយនឹងជំងឺកូវីដ១៩ ដែលនៅក្នុងបណ្តាប្រទេសមួយចំនួនបានកើតមានឡើងវិញជាបណ្តើរៗ ហើយរាប់បញ្ចូលទាំងទីប្រជុំជនមួយចំនួននៅប្រទេសចិន ត្រូវបានដាក់វិធានការណ៍បិទខ្ទប់ និងធ្វើតេស្តមួយសប្តាហ៍៥ដង ដើម្បីទប់ស្កាត់កុំឱ្យមានជំងឺកូវីដ១៩រាតត្បាតបន្តទៀត។ នៅក្នុងតំបន់អឺរ៉ុបត្រូវគេចាត់ទុកថា វាជាតំបន់មានហានិភ័យកំរិតខ្ពស់លើជំងឺអុតស្វា។

**តើជំងឺអុតស្វាគេរកឃើញដំបូងនៅឆ្នាំណា?**

តាមគេហទំព័ររបស់អង្គការសុខភាពពិភពលោកបានឱ្យដឹងកាលពីពេលថ្មីៗនេះថា វីរុសនេះត្រូវបានគេរកឃើញកាលពីឆ្នាំ១៩៧០ ក្នុងនោះរកឃើញភាគច្រើននៅក្នុងតំបន់អាហ្វ្រិក ។ ដោយឡែកក្រៅពីទ្វីប អាហ្វ្រិក កម្រគេប្រទះឃើញនូវវីរុសនេះណាស់ ខណៈដែលក្រុមអ្នកឯកទេសលើវិស័យសុខាភិបាលបានលើកឡើងថា គេតាមដាននិងអង្កេតជាលក្ខណៈវិទ្យាសាស្ត្ររកឃើញថា វីរុសនេះឆ្លងចេញពីសត្វ ។

៥៩



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា






តមកពីទំព័រ ៥៨

**ជំងឺអុតស្វាជាអ្វី?......**

### ជំងឺអុតស្វាជាអ្វី?

ជំងឺអុតស្វា(monkeypox)បង្កឡើងដោយវីរុសមួយប្រភេទមានខ្សែស្រឡាយទៅនឹងជំងឺអុតស្វាយ ហើយវីរុសមានឈ្មោះថា (**orthopoxvirus**) វាមានហ្សែនវីរុសដល់ទៅ២ក្រុម ពោលគឺក្រុមទី១វីរុសឈ្មោះ(**the Congo Basin clade**) ហើយក្រុមទី២ មានឈ្មោះថា (West African clade.)។ វីរុសវង់បូរក្រុមកុងហ្គោរមែងមានសភាពធ្ងន់ធ្ងរជាងវង់បូរវីរុសមួយផ្សេងទៀត។

### ចុះរបៀបឆ្លងវិញ?

ជំងឺអុតស្វា (Monkeypox) គឺជាប្រភេទមេរោគឆ្លងដែលអាចកើតមានទៅលើមនុស្ស និងមនុស្ស រួមទាំងការឆ្លងតាមការរួមភេទដែរ។ រោគសញ្ញារួមមានគ្រុនក្តៅ ហើយកូនកណ្តុរ និងកន្ទួលដែលបង្កើតជាពងបែក ។ ពេលវេលានៃការប៉ះពាល់ទៅនឹងការចាប់ផ្តើមនៃរោគសញ្ញា មានចាប់ពី ប្រាំទៅម្ភៃមួយថ្ងៃ។ រយៈពេលនៃរោគសញ្ញាដែលបង្ហាញឱ្យដឹងគឺជាធម្មតាមានពីចន្លោះចាប់ពីរសប្តាហ៍ទៅបួនសប្តាហ៍ ។ វាអាចមានរោគសញ្ញាស្រាលផ្សេងទៀត ដែលអាចកើតឡើងដោយគ្មានរោគសញ្ញាណាមួយត្រូវបានគេដឹងនោះឡើយ ។ ជាធម្មតាអ្នកជំងឺតែងតែយល់ថាវាជាប្រភេទជំងឺគ្រុនក្តៅធម្មតាដែលមិនសូវចាប់អារម្មណ៍ និងការឈឺចាប់សាច់ដុំ អមដោយក្រពេញហើមជាមួយនឹងដំបៅទាំងអស់នៅដំណាក់កាលតែមួយ មិនត្រូវបានរកឃើញហើយគេតែងគិតថា វាជារឿងធម្មតាចំពោះការផ្ទុះឡើងទាំងអស់ ។ ករណីអាចធ្ងន់ធ្ងរ ជាពិសេសចំពោះកុមារ ស្ត្រីមានផ្ទៃពោះ ឬអ្នកដែលមានប្រព័ន្ធការពាររាងកាយចុះខ្សោយខ្លាំង ។

ជំងឺនេះបង្កឡើងដោយមេរោគអុតស្វាដែលជាប្រភេទមេរោគ (zoonotic) នៅក្នុងពីជហ្សែនឈ្មោះ(genus Orthopoxvirus) ។ តាមសេចក្តីរាយការណ៍បានឱ្យដឹងបន្ថែមទៀតថា ប្រភេទមេរោគ ឈ្មោះ ( **វ៉ារីអូឡា**) វាជាភ្នាក់ងារបង្កជំងឺអុតស្វាក៏មាននៅក្នុងប្រភេទនេះដែរ ។ ក្នុងចំណោមវីរុសពីរប្រភេទ ដែលបាននិងកំពុងតែកើតមានឡើងចំពោះមនុស្សពោល គឺប្រភេទអាហ្វ្រិកខាងលិចបង្កឱ្យមានជំងឺមិនសូវធ្ងន់ធ្ងរជាងប្រភេទអាហ្វ្រិកកណ្តាល (ត្រង់តំបន់វាលទំនាបប្រទេសកុងហ្គោ) ។ វាអាចឆ្លងពីសត្វដែលមានមេរោគដោយការគ្រប់គ្រងសាច់ដែលមានមេរោគ ឬតាមរយៈការខាំឬកោស ។ ការឆ្លងពីមនុស្សទៅមនុស្សអាចកើតមានឡើងតាមរយៈការប៉ះពាល់នឹងវត្ថុរាវក្នុងរាងកាយដែលមានមេរោគ និងវត្ថុដែលមានមេរោគ តាមរយៈដំណក់ទឹកមាត់តូចៗឬអាចតាមរយៈបរិយាកាសផងដែរ ។ អ្នកជំងឺអាចចម្លងមេរោគតាំងពីការចាប់ផ្តើមនៃរោគសញ្ញាដំបូង រហូតដល់ដំបៅទាំងអស់មានស្នាម និងលេចរូបរាងចេញមក ។ តាមរយៈភស្តុតាងខ្លះនៃការរីករាលដាលអស់រយៈពេលជាងមួយសប្តាហ៍បន្ទាប់ពីដំបៅ



ការការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល








បានប្រេះស្នាម ។ ការធ្វើរោគវិនិច្ឆ័យចំពោះវីរុសប្រភេទនេះ មានតែបញ្ជាក់តាមរយៈការធ្វើតេស្តដំបៅឆ្លងកាត់តាមប្រព័ន្ធទិន្នន័យព័ត៌មានជាតិពន្ធុ(DNA) របស់មេរោគ។ គេនៅមិនទាន់រកឃើញវិធីសាស្ត្រព្យាបាលប្រកបដោយប្រសិទ្ធភាពដែលគេស្គាល់ទេនៅឡើយទេ ក្រៅតែពីការចាក់វ៉ាក់សាំងនោះ ។ ផ្អែកតាមការសិក្សាមួយក្នុងឆ្នាំ ១៩៩៨ បានរកឃើញថាវ៉ាក់សាំងជំងឺអុតស្វាយមានប្រហែល ៨៥% អាចការពារក្នុងការឆ្លងមេរោគក្នុងទំនាក់ទំនងជិតស្និទ្ធ និងក្នុងការកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺនេះ ។ វ៉ាក់សាំងជំងឺអុតស្វាយថ្មីនិងជំងឺគ្រុនស្វាដោយផ្អែកលើវ៉ាក់សាំងដែលបានកែប្រែ ត្រូវបានអនុម័ត ប៉ុន្តែជាមួយនឹងភាពអាចរកបានមានកំណត់។ មានវិធានការផ្សេងទៀតដែលអាចរួមចំណែកកាត់បន្ថយការឆ្លងបានក្នុងនោះរួមមានការលាងដៃជាប្រចាំនិងជៀសវាងកុំឱ្យប៉ះពាល់ដោយផ្ទាល់ជាមួយនឹងអ្នកជម្ងឺ និងសត្វមានជម្ងឺជាដើម ។ ថ្នាំប្រឆាំងវីរុសមានប្រភេទ(cidofovir) និង (teco - virimat) វ៉ាក់សាំង (globulin) និងវ៉ាក់សាំងជំងឺអុតស្វាយអាចត្រូវបានគេប្រើក្នុងអំឡុងពេលផ្ទុះជម្ងឺអុតស្វា។ ជំងឺនេះជាធម្មតាស្រាល ហើយភាគច្រើននៃអ្នកឆ្លងនឹងជាសះស្បើយក្នុងរយៈពេលពីរបីសប្តាហ៍ដោយគ្មានការព្យាបាល ។ ការប៉ាន់ប្រមាណនៃហានិភ័យនៃការស្លាប់ប្រែប្រួលពី ១% ទៅ១៩% ទោះបីជាការស្លាប់តិចតួចដែលជាផលវិបាកនៃជំងឺអុតស្វាត្រូវបានគេកត់ត្រាតាំងពីឆ្នាំ ២០១៧ មកម្ល៉េះ ៕

អត្ថបទ ៖ អនុសេនីយ៍ទោ

ប្រាក់ សម្ផស្ស

ប្រភព ៖ ឯកសារបរទេស



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# កម្លាំងនគរបាលអន្តរាគមន៍ពិសេស នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ ចំនួន ៤៥នាក់ ហ្វឹកហាត់ជំនាញ ដើម្បីពង្រឹងសមត្ថភាព បម្រើកិច្ចប្រតិបត្តិការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សុវត្ថិភាពសង្គម



ថ្មីៗកន្លងមកនេះ កងកម្លាំងនគរបាលអន្តរាគមន៍ពិសេសនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចំនួន ៤៥នាក់ បានចូលរួមហ្វឹកហាត់បាញ់គ្រាប់ពិតរយៈពេល២សប្តាហ៍ នៅលើទីលានបាញ់គ្រាប់ពិតសាលាមិត្តភាពកម្ពុជា-វៀតណាម នៅក្នុងខេត្តកំពង់ស្ពឺ ដើម្បីពង្រឹងសមត្ថភាពជំនាញ បំរើឱ្យកិច្ចប្រតិបត្តិការបង្ការ ទប់ស្កាត់បទល្មើសគ្រប់ប្រភេទឱ្យកាន់តែមានប្រសិទ្ធភាព សំដៅចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព សង្គមឱ្យកាន់តែល្អប្រសើរ ។

លោកវរសេនីយ៍ទោ **អ៊ុន ប៊ុនធឹម** នាយការិយាល័យអន្តរាគមន៍ និងកម្រេតបទបញ្ជានៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានបញ្ជាក់ឲ្យដឹងថា៖ ការហ្វឹកហាត់របស់កម្លាំងអន្តរាគមន៍ពិសេសនៅពេលនេះគឺអនុវត្តតាមគោលការណ៍ដឹកនាំបញ្ជាផ្ទាល់ពី ឧត្តមសេនីយ៍ឯក **ស ថេត** អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ដើម្បីហ្វឹកហាត់បំប៉នទាំងស្មារតី និង











៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



ជំនាញប្រើប្រាស់អាវុធឱ្យបានត្រឹមត្រូវតាមយុទ្ធវិធី ក្នុងការបាញ់ឲ្យចំគោលដៅ និងការពារខ្លួនពីសត្រូវដែលមានអាវុធ តាមរយៈកាយវិកាចលិតដើរបាញ់ចំនួន ៤គ្រាប់ បាញ់គ្រាប់ពិតកាយវិកាចលិតដើរទៅមុខឈរបាញ់ បាញ់គ្រាប់ពិតកាយវិការត់ត្រឡប់ក្រោយមានរនាំងការពារ បាញ់ខាងឆ្វេង និងខាងស្តាំបាញ់គ្រាប់ពិតកាយវិកាឈរត្រឡប់ក្រោយបែរបាញ់ឱ្យចំគោលដៅដោយមានការចូលរួមបង្ហាត់បង្រៀនពីសំណាក់ក្រុមគ្រូបង្គោលចំនួន ១០នាក់ ដែលបណ្តុះបណ្តាលនៅក្នុងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាមផ្ទាល់ ។











៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សកម្មភាពប្រតិភូ ស ម ន នាំយក ថវិកាផ្តល់ជូនដល់គ្រួសារសព សមាជិក-សមាជិកា ដែលទទួលមរណភាព និងបាត់បង់សមត្ថភាពការងារ



**ឧត្តមសេនីយ៍ឯក ស្ងួន គឹមស៊ាន់** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ អញ្ជើញប្រគល់ថវិកា ស ម ន ជូនលោកស្រី ដិប សុខសេរីវតី ត្រូវជាភរិយាសពលោកវរសេនីយ៍ទោ នួន តេជៈ។

**ឧត្តមសេនីយ៍ទោ សម្បត្តិ សុធារដ្ឋ** ប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកែប ប្រគល់ថវិកា ស ម ន ជូនដល់លោកស្រី ហ៊ុន សារិត ត្រូវជាភរិយាសពលោកអនុសេនីយ៍ឯក គង់ វុទ្ធី។





**ឧត្តមសេនីយ៍ត្រី ដួង ស៊ីហៀ** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋាននគរបាលការពារព្រំដែនគោក ប្រគល់ថវិកា ស ម ន ជូនលោកស្រី ស៊ឹម គី ត្រូវជាភរិយាសពលោកអនុសេនីយ៍ទោ ឃឹម កែវ។

**ឧត្តមសេនីយ៍ត្រី ស្រ៊ី សុវណ្ណ** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ប្រគល់ថវិកា ស ម ន ជូនដល់លោកស្រី អ៊ូ ពុទ្ធារី ត្រូវជាកូនបង្កើតសពលោកវរសេនីយ៍ត្រី ស៊ូ សារួន។



សូមលំអោនកាយរំលែកទុក្ខយ៉ាងក្រៀមក្រំ ចំពោះមន្ត្រីនគរបាលជាតិ ដែលបានពលីជីវិតក្នុងបេសកកម្មនានានៃបុព្វហេតុជាតិ មាតុភូមិ និង សូមបួងសួងឱ្យវិញ្ញាណក្ខន្ធបងប្អូន ឆាប់បានទៅកាន់សុខគតិភព។



**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



**ឧត្តមសេនីយ៍ទោ សុខ សំសោភណ្ឌា** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានផ្សព្វផ្សាយអប់រំ ប្រគល់ថវិកា ស ម ន ជូនដល់លោកស្រី ប៉ាត លឿង ត្រូវជាភរិយាសពលោកវរសេនីយ៍ត្រី ស្រី ស៊ីមលន់ ។

**ឧត្តមសេនីយ៍ត្រី វង្ស វិត** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ប្រគល់ថវិកា ស ម ន ជូនដល់គ្រួសារសពលោកអនុសេនីយ៍ឯក ឆោម ភក្តី ។





**វរសេនីយ៍ឯក ប៊ូ ដារ៉ារិទ្ធ** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានច្រកទ្វារទី ២ ប្រគល់ថវិកា ស ម ន ជូនដល់លោកស្រី សុខ ស្រីនាង ត្រូវជាភរិយាសពលោកឡុញ គីមលី មន្ត្រីចូលនិវត្តន៍ ។

**ឧត្តមសេនីយ៍ត្រី សេង គឹមឃន** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកណ្តាលប្រគល់ថវិកា ស ម ន ជូនលោកស្រី ហ៊ិន សេងហ៊ុយ ត្រូវជាភរិយាសពលោកអនុសេនីយ៍ត្រី នៅ ស៊ីថន ។





**វរសេនីយ៍ឯក អៀង មករា** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តសៀមរាប ប្រគល់ថវិកា ស ម ន ជូនលោកស្រី ស៊ុយ ចាន់នី ត្រូវជាភរិយាសពលោកអនុសេនីយ៍ទោ ឆាយ ចាន់ថុល ។

**វរសេនីយ៍ឯក ស្វាយ ស៊ីប៊ុណ្ណា** លេខាធិការគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ប្រគល់ថវិកា ស ម ន ជូនលោកស្រី សុខ ស៊ីណា ត្រូវជាភរិយាសពលោកអនុសេនីយ៍ឯក ណុប វណ្ណី ។





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា


SOKIMEX INVESTMENT GROUP
ក្រុមហ៊ុន សូគីម៉ិច អ៊ិនវេសមេន គ្រុប
SOKIMEX INVESTMENT GROUP CO., LTD.
SOKHA
សណ្ឋាគារ និងរមណីយដ្ឋានសុខា
Sokha Hotels & Resorts
+855 23 91 91 91
THANSUR SOKHA Hotel
LE BOKOR PALACE
បូកគោ
ក្រុមហ៊ុនបូកគោហ្វាម ឯ.ក
Bokor Farm Co.,Ltd.
+855 88 2636358 | +855 88 9494614
SOKIMEX
ស្ថានីយប្រេងឥន្ធនៈសូគីម៉ិច
Sokimex Petroleum Station
SOKHA REAL ESTATE
ក្រុមហ៊ុនសុខារៀលអ៊ីស្តេត ឯ.ក
Sokha Real Estate Co., Ltd.
+855 98 200 777
#22 Kramuon Sar,Sangkat Phsar Thmey 2, Daun Penh, Phnom Penh Cambodia
Tel: (855) 23 998 918,Fax: (855) 23 998 920| E-mail: info@skmig.com | Website: www.skmig.com